# របាយការណ៍ប្រចាំឆ្នាំ

# 2015

FROM SINGAPORE TO CAMBODIA



PhillipBank

Your Partner In Finance



# មាតិកា


| | |
|---|---|
| សារគារ | ០៣ |
| ទីតាំងសាខាធនាគារ | ០៤ |
| បេសកម្មរបស់ក្រុមហ៊ុន | ០៥ |
| សេចក្តីថ្លែងការរបស់ប្រធានក្រុមប្រឹក្សាភិបាល | ០៦ |
| សេចក្តីសង្ខេបហិរញ្ញវត្ថុ | ០៩ |
| សេចក្តីសង្ខេបលើការប្រតិបត្តិហិរញ្ញវត្ថុរបស់ធនាគារ ក្នុងរយៈពេល ៣ឆ្នាំ | ១០ |
| ការវិភាគលើលទ្ធផលហិរញ្ញវត្ថុ | ១៣ |
| រចនាសម្ព័ន្ធរបស់ធនាគារ | ១៥ |
| ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល | ១៦ |
| ប្រវត្តិរូបគណៈគ្រប់គ្រង | ១៨ |
| គុណតម្លៃ / ធនធានរបស់យើង | ២៣ |
| ទំនួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម | ២៤ |

**របាយការណ៍ហិរញ្ញវត្ថុ**

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ២៥
- របាយការណ៍របស់សវនករឯករាជ្យ ២៩
- តារាងតុល្យការរួម ៣០
- របាយការណ៍លទ្ធផលរួម ៣១
- របាយការណ៍បម្រែបម្រួលមូលធនរួម ៣២
- របាយការណ៍លំហូរសាច់ប្រាក់រួម ៣៣
- តារាងតុល្យការដាច់ដោយឡែក ៣៤
- របាយការណ៍លទ្ធផលដាច់ដោយឡែក ៣៥
- បម្រែបម្រួលមូលធនដាច់ដោយឡែក ៣៦
- របាយការណ៍លំហូរសាច់ប្រាក់ដាច់ដោយឡែក ៣៧
- កំណត់សម្គាល់លើរបាយកាណ៍ហិរញ្ញវត្ថុ ៣៨




ធនាគារហ្វងឌីប៊ីអេស ពាណិជ្ជ ភីអិលស៊ីបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៦ មិថុនា ២០០៩។ ធនាគារជាបុត្រសម្ព័ន្ធកាន់កាប់ទាំងស្រុងដោយ Hwang-DBS (Malaysia) Berhad ជាធនាគារមហាជនទទួលខុសត្រូវមានកម្រិតដែលចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសម៉ាឡេស៊ី។

នៅថ្ងៃទី៨ វិច្ឆិកា ២០១៣កន្លងទៅនេះធនាគារហ្វងឌីប៊ីអេសបានចុះកិច្ចព្រមព្រៀងទិញលក់ភាគហ៊ុនរបស់ខ្លួន ជាក្រុមហ៊ុន Phillip MFIs Pte Ltd។ ការផ្ទេរសិទ្ធ និងអត្ថប្រយោជន៍ត្រូវបានទទួលការយល់ព្រមពីធនាគារជាតិ នៃកម្ពុជានៅថ្ងៃទី១១ ខែកុម្ភៈ ២០១៤។ ក្រោមពីទទួលការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ធនាគារបានដាក់ពាក្យមួយទៀតទៅក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៣ ខែ កុម្ភៈ ២០១៤ ដើម្បីបញ្ជាក់ពីការកែប្រែអនុស្សរណៈ និងលក្ខន្តិកៈដើម្បីប្តូរឈ្មោះអោយទៅជាធនាគារហ្វីលីព ភីអិលស៊ី។ ការកែប្រែនេះត្រូវបានអនុម័តយល់ព្រមដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី២៤ កុម្ភៈ ២០១៤។

ធនាគារនេះបានចូលរួមក្នុងការផ្តល់សេវាធនាគារដ៏ទូលំទូលាយ និងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាតាមអាជ្ញាប័ណ្ណលេខ ៥៩១៥/០៩E ដែលចេញដោយធនាគារជាតិ នៃកម្ពុជាសម្រាប់រយៈពេលមិនកំណត់។

អាស័យដ្ឋានការិយាល័យដែលបានចុះបញ្ជីគឺផ្ទះលេខ ២៧DEF មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាច្រកកម្ពុជា។

# ទីតាំងសាខាធនាគារ



### ការិយាល័យ កណ្តាលសាខា មុន្នីវង្ស
#27DEF, Monivong Blvd., Sangkat Srah Chork,
Khan Daun Penh, Phnom Penh
Telephone: +855 23 862 777
Fax : +855 23 862 727
Email : info@phillipbank.com.kh

### សាខា នរោត្តម
#61-64 Norodom Blvd., Corner Street 306,
Sangkat Boeung Keng Kang 1, Khan Chamkarmorn,
Phnom Penh
Telephone: +855 23 218 866
Fax : +855 23 220 108
Email : nrd@phillipbank.com.kh

### សាខា កម្ពុជាក្រោម
#640, Kampuchea Krom Blvd., Phsar Depo 2,
Khan Toul Kork, Phnom Penh
Telephone: +855 23 883 733
Fax : +855 23 883 811
Email : kpk@phillipbank.com.kh

### សាខា ម៉ៅសេទុង
#108AB, Mao Tse Tung Blvd., Sangkat Toul Tompung 2,
Khan Chamkarmorn, Phnom Penh
Telephone: +855 23 220 080
Fax : +855 23 220 081
Email : mtt@phillipbank.com.kh

### សាខា ស្ទឹងមានជ័យ
#6B – 7B, Street Preah Monireth,
Sangkat Steung Meanchey, Khan Meanchey, Phnom Penh
Telephone: +855 23 424 220
Fax : +855 23 424 221
Email : smc@phillipbank.com.kh

### សាខា ទឹកថ្លា
#11A & 13A, Russian Confederation Blvd.,
Sangkat Teuk Thla, Phnom Penh
Telephone: +855 23 888 828
Fax : +855 23 888 838
Email : tta@phillipbank.com.kh

Facebook: PhillipBank Cambodia
Website: www.phillipbank.com.kh

# បេសកម្មរបស់ក្រុមហ៊ុន

ធ្វើការកែប្រែខ្លួនអោយទៅជាក្បាលម៉ាស៊ីនផ្នែកធនាគារពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព និងមានការធានាដំបូងដែលបានផ្សារភ្ជាប់អតិថិជនរបស់យើងទៅនឹងរាល់តម្រូវការផ្នែកធនាគាររបស់គេដើម្បីឆ្លើយតបទៅនឹងពាក្យស្លោករបស់យើងដែលថា ដៃគូហិរញ្ញវត្ថុរបស់អ្នក។

## ចក្ខុវិស័យរបស់ក្រុមហ៊ុន

### យើងខ្ញុំប្តេជ្ញានឹង៖

- ធ្វើអោយប្រជាជនកម្ពុជាទទួលបានសេវាកម្មធនាគារប្រកបដោយសុវត្ថិភាពនិងមានសន្តិសុខខ្ពស់
- ផ្តល់ជូននូវការយកចិត្តទុកដាក់ជាពិសេស និងឧត្តមភាពនៃសេវាកម្ម ហើយធានាថាយើងនឹងក្លាយ ជាធនាគារដែលស្ថិតក្នុងជម្រើសអតិថិជន
- គោរពពាក្យសន្យារបស់យើងដោយផ្តល់ជូននូវសេវាកម្មធនាគារប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ផលិតផលថ្មី និងសេវាកម្មធនាគារដែលមានបច្ចេកវិទ្យាខ្ពស់ដើម្បីបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុ និង ធនាគាររបស់អតិថិជន
- ការពារឧត្តមប្រយោជន៍របស់អតិថិជនដោយព្យាករណ៍អំពីតម្រូវការដើម្បីផ្តល់ជូនដំណោះស្រាយពាក់ព័ន្ធក្នុងអាជីវកម្មដើម្បីលើកកម្ពស់ការរីកចម្រើនរបស់ពួកគេ។
- បន្តពុះពារនិងផ្តោតសំខាន់ទៅលើការធ្វើអោយប្រសើរឡើងនូវនិយោជិត ផលិតផល សេវាកម្ម ធនធានរបស់យើងដើម្បីបម្រើជូនអតិថិជនរបស់យើងអោយកាន់តែប្រសើរ។

## ទស្សនៈរបស់ក្រុមហ៊ុន

### ទស្សនៈវិស័យរបស់អតិថិជន

- ផ្តល់សេវាកម្មធនាគារប្រកបដោយប្រសិទ្ធភាព និងមានការធនាដល់យើង
- ផ្សារភ្ជាប់អតិថិជនរបស់យើងជាមួយនឹងរាល់តម្រូវការផ្នែកធនាគាររបស់ពួកគាត់

### ទស្សនៈវិស័យរបស់និយោជិត

- និយោជិតរបស់យើងគឺជាធនធានដ៏មានសារៈសំខាន់បំផុតរបស់យើង។ ដោយសារហេតុនេះហើយទើបយើងប្រកាន់យកការអភិវឌ្ឍធនធានរបស់យើងជាកត្តាចាំបាច់។ ដំណើរការអភិវឌ្ឍធនធាន មនុស្សប្រកបដោយអានុភាព នឹងធ្វើអោយធនាគាររបស់យើងមានសមត្ថភាពប្រកួតប្រជែងកាន់តែខ្លាំង។

### ទស្សនៈវិស័យសហគមន៍

- គាំទ្រដល់គោលនយោបាយ និងវត្ថុបំណងរបស់រដ្ឋាភិបាល និងនាំមកនូវភាពប្រសើរឡើងដល់សហគមន៍ និងប្រទេសជាតិ។

### ទស្សនៈវិស័យរបស់ម្ចាស់ភាគហ៊ុន

- បង្កើតអោយមានតម្លៃដ៏ឧត្តមនៃភាគទុនិក និងជាមួយផលកម្រៃពីទ្រព្យបង្វែរ។

## ទិដ្ឋភាពធុរកិច្ចទូទៅ

យោងតាមរបាយការណ៍របស់ធនាគារពិភពលោក ប្រទេសកម្ពុជានៅតែបន្តមានកំណើនរឹងមាំ ទោះបីជានៅមានកម្រិតទាបជាងឆ្នាំ ២០១៥ បន្តិចក៏ដោយ ។ វិស័យកាត់ដេរ រួមជាមួយសំណង់ និងសេវាកម្មនៅតែបន្ត ជំរុញកំណើនសេដ្ឋកិច្ច។ ដោយឡែក ការព្យាករសម្រាប់ឆ្នាំ២០១៥ និង ឆ្នាំ២០១៦ បានបញ្ជាក់ថាកំណើនសេដ្ឋកិច្ចគឺមានប្រហែល ៦,៩% ដោយប្រទេសនេះកំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងក្នុងវិស័យកាត់ដេរសម្រាប់នាំចេញ ការរីកចម្រើនលើវិស័យកសិកម្មនៅមានភាពទន់ខ្សោយនិងកំនើនលើវិស័យទេសចរណ៍នៅមានកម្រិត។

ធនាគារពិភពលោកព្យាករថា សេដ្ឋកិច្ចរបស់ប្រទេសនេះ នឹងបន្តធ្លាក់ចុះបន្តិចម្តងៗក្នុងរយៈពេលពីរបីឆ្នាំបន្ទាប់នេះ ហើយថា ការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិននឹងជះឥទ្ធិពលតិចតួចមកលើកម្ពុជា។ ទោះជាមានការវិនិយោគផ្ទាល់ធំៗពីទីក្រុងប៉េកាំងនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ប្រទេសកម្ពុជាមិនមានរងនូវផលប៉ះពាល់ធ្ងន់ធ្ងរដែរ ដោយប្រទេសនេះមានគំលាតគ្រប់គ្រាន់ពីសេដ្ឋកិច្ចរបស់ប្រទេសចិន។

ទោះជាយ៉ាងណា កម្ពុជានឹងមានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ជាមួយនឹងមូលនិធិរូបិយវត្ថុអន្តរជាតិ( **IMF** )នៅក្នុងរបាយការណ៍របស់ចុងក្រោយនេះ “ចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក” បានព្យាករណ៍ថាអត្រាមធ្យមប្រចាំឆ្នាំ ៧,៣% រហូតដល់ ឆ្នាំ ២០២០។ ទោះជាយ៉ាងណា អត្រានៃកំណើននាពេលអនាគតនឹងក្លាយជាសញ្ញាសួរដ៏ធំមួយ ប្រសិនបើប្រទេសកម្ពុជាមិនអាចបង្កើនការប្រកួតប្រជែង និង បរិយាកាសវិនិយោគរបស់ខ្លួន។

**IMF** បានព្រមានថា កំណើនឥណទានយ៉ាងឆាប់រហ័ស ហិរញ្ញប្បទានកាន់តែខ្លាំងឡើងដោយលំហូរធនាគារពីបរទេស បង្កហានិភ័យធ្ងន់ធ្ងរដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងតម្រូវឱ្យមានគោលនយោបាយផ្តល់ប្រាក់កម្ចី និងកាត់បន្ថយទំហំនៃប្រាក់កម្ចី។ ការសន្និដ្ឋានរបស់ **IMF** គឺថា ជាចំបងប្រទេសនេះត្រូវដោះស្រាយការកើនឡើងហានិភ័យលើស្ថេរភាពហិរញ្ញវត្ថុតាមរយៈការធ្វើឲ្យមានស្ថិរភាពនិងការបន្ថយល្បឿននៃកំណើនឥណទានក្នុងកម្រិតមួយសមហេតុសមផលជាងនេះ ហើយក៏ត្រូវតាមដានយ៉ាងល្អិតល្អន់លើឥទ្ធិពលនៃកំណើន។

ធនាគារជាតិនៃ កម្ពុជា ( **NBC** ) បានឱ្យដឹងថា នៅក្នុងរបាយការណ៍ចុងឆ្នាំ ២០១៥ របស់ខ្លួន សក្តានុពលនៃសេដ្ឋកិច្ចពិភពលោកនិងក្នុងតំបន់ទំនងជានឹងបង្កបញ្ហាប្រឈម សម្រាប់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០១៦។ របាយការណ៍នេះបានបង្ហាញពីរបៀបដែលកំណើនសេដ្ឋកិច្ចអាមេរិករឹងមាំ ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងប្រទេសចិន និងអឺរ៉ុប និងការកើនឡើងការប្រកួតប្រជែងក្នុងតំបន់ដោយត្រូវបានគេរំពឹងថានឹងធ្វើការសាកល្បងភាពធន់ទ្រាំនៃម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

ការកើនឡើងប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យកាត់ដេរ ការកើនឡើងការប្រកួតប្រជែងបន្ទាប់ពីការអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូឆ្លងកាត់ប៉ាស៊ីហ្វិក កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងវៀតណាម និងសហភាពអឺរ៉ុបនិងសេរីភាវូបនីយកម្មសេដ្ឋកិច្ចនៅក្នុងប្រទេសមីយ៉ាន់ម៉ា មានសក្តានុពលក្នុងការថ្លឹងថ្លែងការប្រកួតប្រជែងក្នុងតំបន់របស់កម្ពុជា។

ប៉ុន្តែ ទោះបីជាទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចសកលមានការប្រកួតប្រជែង ធនាគារជាតិនៃកម្ពុជាមានទំនុកចិត្តថា ប្រទេសកម្ពុជាអាចរក្សាកំណើនសេដ្ឋកិច្ចរឹងមាំសម្រាប់ឆ្នាំខាងមុខនេះ ដោយរបាយការណ៍នោះបញ្ជាក់អំពីការ ខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញអោយប្រទេសមានលទ្ធភាពទប់ទល់នឹងផលប៉ះពាល់ពីខាងក្រៅនឹង ការរីករាលដាលពីបរិយាកាសអន្តរជាតិ។

## សេចក្តីសង្ខេបលើប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ

ក្នុងឆ្នាំ ២០១៥ ធនាគារ ហ្វីលីព ភីអិលស៊ី។ ("ធនាគារ") បានបន្តយុទ្ធសាស្ត្រ និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកំណត់គោលដៅក្រុមជាក់លាក់ លើសហគ្រាស និងពាណិជ្ជករខ្នាតមធ្យម អ្នកទិញផ្ទះលំនៅដ្ឋាន និងការលក់ដុំនូវសេវាកម្មធនាគារទៅឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើផ្សេងៗ។ ធនាគារនេះបានកត់ត្រាប្រាក់ចំណូលប្រតិបត្តិការសរុបរបស់ខ្លួនចំនួន ៣,៦២ លានដុល្លារ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥( បើប្រៀបធៀបទៅនឹងទឹកប្រាក់ចំនួន ៣,១៥ លានដុល្លារសម្រាប់ឆ្នាំមុន ) ដោយកើនឡើង ១៤,៩% ។ ផលប័ត្រឥណទានកម្ចីបានកើនឡើងដល់ ៦៨,៤៨ លានដុល្លារ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ បើប្រៀបធៀបទៅនឹងចំនួនទឹកប្រាក់ ៣៧,៨២លានដុល្លារក្នុងមួយឆ្នាំមុនមានការកើនឡើង ៨២,២% ។ ស្រដៀងគ្នានេះដែរ ប្រាក់បញ្ញើក៏បានកើនឡើងយ៉ាងខ្លាំង ពី ៤៥ លានដុល្លារ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ ដល់ ៦២ លានដុល្លារ នៅថ្ងៃទី ៣១ ខែធ្នូ ២០១៥។ លទ្ធផលជាវិជ្ជមានក្នុងការចាប់យកឱកាសពេលនេះឆ្លុះបញ្ចាំងពីភាពជោគជ័យនៃការផ្តួចផ្តើម ជាច្រើនរបស់ធនាគារក្នុងរយៈពេលពេញមួយឆ្នាំ ដែលរួមបញ្ចូលការបើកសាខាថ្មីចំនួនពីរកន្លែងនៅទឹកថ្លា និង មុន្នីវង្ស និងការដាក់ទីតាំងថ្មីការិយាល័យកណ្តាលទៅក្នុងបរិវេណដែលមានទំហំធំនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស។

ទោះជាយ៉ាងណា ជាលទ្ធផលនៃការចំណាយមូលធនសម្រាប់ការផ្តួចផ្តើមខាងលើនេះ គួបផ្សំជាមួយការចំណាយការប្រាក់ខ្ពស់ដើម្បីបង្កើនមូលដ្ឋានប្រាក់បញ្ញើរបស់ខ្លួន ធនាគារបានកត់ត្រាការខាតបង់មុនការបង់ពន្ធចំនួន ០,៣០ លានដុល្លារ ( បើប្រៀបធៀបទៅនឹងប្រាក់ចំណេញមុនការបង់ពន្ធចំនួន ០,២០ លានដុល្លារសម្រាប់ឆ្នាំមុន )។ ទោះជាយ៉ាងណា ធនាគារសម្រេចបាននូវផលវិជ្ជមានមុនពេលបង់ពន្ធការរំលោះថេរ និងការបង់រំលោះចំនួន ៧៥.២៧៩ ដុល្លារក្នុងឆ្នាំ ២០១៥។ យើងមានសេចក្តីសោមនស្សរីករាយណាស់ដោយចាប់តាំងពីខែកញ្ញា ឆ្នាំ ២០១៥ រហូតដល់បច្ចុប្បន្ន ធនាគារសម្រេចបាននូវប្រាក់ចំណេញសុទ្ធមុនពេលបង់ពន្ធលើមូលដ្ឋានប្រចាំខែជាបន្តបន្ទាប់។

ធនាគារបានបង្កើនដើមទុនរបស់ខ្លួនពី ៤០ លានដុល្លារ ដល់ ៤១ លានដុល្លារ ក្នុងឆ្នាំ ២០១៥។ ដើមទុននេះគឺខ្ពស់ជាងតម្រូវការមូលធនអប្បបរមាយ៉ាងហោចណាស់ ១៥០ ពាន់លាន ( ឬ ៣៧,៥០ លានដុល្លារ ) ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា។

## ការអនុលោមតាមបទប្បញ្ញត្តិដែលចេញដោយធនាគារកណ្តាល

ធនាគារនៅតែប្រកាន់ខ្ជាប់ និងអាចរក្សាការអនុវត្តដោយអនុលោមបទប្បញ្ញត្តិ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា (**NBC**)។ ធនាគារប្តេជ្ញារក្សាឲ្យបាននូវអភិបាលកិច្ចអាជីវកម្មល្អ និងវិជ្ជាជីវៈក្នុងការគ្រប់គ្រង និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។ ធនាគារបន្តអនុវត្តតាមយ៉ាងតឹងរ៉ឹងតាមប្រកាស សារាចរ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។ ចុងបញ្ចប់នេះ ធនាគារក៏បានបន្តវិនិយោគនៅក្នុងវិស័យបច្ចេកវិទ្យា និង សន្តិសុខហេដ្ឋារចនាសម្ព័ន្ធផងដែរ។

## វិធានការដើម្បីពង្រឹងជំហរ និងការអនុវត្តរបស់ធនាគារ

ធនាគារមានគោលបំណងដើម្បីក្លាយជាអ្នកដើរតួរសំខាន់ និងមានប្រយោជន៍នៅក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់ជូនអតិថិជនរបស់ខ្លួននូវតម្រូវការក្នុងវិស័យធនាគារដែលប្រកបដោយសុវត្ថិភាព ប្រសិទ្ធិភាព និងរហ័ស នៅក្នុងប្រទេសកម្ពុជា ព្រមទាំងទៅកាន់ទីផ្សារផ្សេងៗទៀតនៅក្នុងតំបន់អាស៊ីផងដែរ។ ដូច្នេះហើយ ធនាគារបានប្តេជ្ញាចិត្តដើម្បីវាយតម្លៃ និងកែលម្អសេវារបស់ខ្លួនជានិច្ចដើម្បីផ្តល់នូវបទពិសោធន៍ និងសេវាកម្មដ៏ល្អសម្រាប់អតិថិជន។

ក្នុងឆ្នាំ ២០១៥ ធនាគារបានបន្តទំនាក់ទំនងល្អប្រសើរជាងមុនជាមួយអតិថិជនរបស់យើង ហើយជាលទ្ធផលមូលដ្ឋានប្រាក់បញ្ញើលក់រាយនឹងផលប័ត្រប្រាក់កម្ចីរបស់យើងមានការកើនឡើងជាលំដាប់។ ការរើការិយាល័យកណ្តាលរបស់ធនាគារពីតាមបណ្តោយមហាវិថីព្រះនរោត្តម ទៅផ្លូវព្រះមុនីវង្ស និងការបើកសាខាថ្មីទាំងពីរកន្លែង ជាផ្នែកមួយនៃយុទ្ធសាស្ត្ររយៈពេលយូរដើម្បីពង្រីកបណ្តាញចែកចាយរបស់ខ្លួន។

ធនាគារក៏បានដំឡើងម៉ាស៊ីន អេ ធី អឹម នៅនឹងកន្លែងចំនួនបីកន្លែងផងដែរ នៅរាជធានីភ្នំពេញ ក្នុងឆ្នាំ ២០១៥ និងកំពុងគម្រោងដំឡើងម៉ាស៊ីន អេ ធី អឹម បន្ថែមចំនួនបួនកន្លែងទៀត នៅក្នុងទីក្រុង នៅឆ្នាំ ២០១៦ ដើម្បីបង្កភាពងាយស្រួលដល់អតិថិជនរបស់យើង ក្នុងការធ្វើប្រតិបត្តិការធនាគាររបស់ពួកគេ ២៤ ម៉ោង ក្នុងមួយថ្ងៃ។

ក្នុងអំឡុងពេលមួយឆ្នាំពេញ ធនាគារបានសហការជាមួយ **True Money Cambodia Plc** ដើម្បីតែងតាំងពួកគេជា ភាគីទីបីរបស់ខ្លួន ដើម្បីផ្តល់នូវសេវាផ្ទេរប្រាក់ក្នុងស្រុកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ នេះគឺជាផ្នែកមួយ នៃយុទ្ធសាស្ត្ររបស់ធនាគារក្នុងការផ្តល់ជំនួយទៅឱ្យអតិថិជនដែលមិនមានគណនីធនាគារ ហើយក៏ដើម្បីពង្រីកការចែកចាយរបស់ខ្លួនផងដែរ។

ជាចុងក្រោយ ធនាគារនឹងបន្តធ្វើការស្រាវជ្រាវទីផ្សារ និងស្វែងរកឱកាសក្នុងការផ្តល់ជំនួយនិងសេវាហិរញ្ញវត្ថុទៅក្នុងទីផ្សារដែលខ្វះខាតការផ្គត់ផ្គង់ដោយធ្វើការ ធានាឲ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ គោលនយោបាយគ្រប់គ្រងហានិភ័យ និងគោលនយោបាយនិងនីតិក្រមឥណទានដ៏ហ្មត់ចត់។

## ការផ្តោតការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តរបស់ប្រធានក្រុមប្រឹក្សាភិបាល

ធនាគារនៅតែប្រឹងប្រែងយ៉ាងខ្លាំង និងប្តេជ្ញាចិត្តក្នុងការផ្តល់តម្លៃដល់ភាគីពាក់ព័ន្ធទាំងអស់។

ក្នុងនាមជាផ្នែកមួយនៃ **PhillipCapital Group** ធនាគារនឹងបន្តបង្កើនទុនលើសមត្ថភាពស្នូលរបស់ក្រុមក្នុងវិស័យហិរញ្ញវត្ថុ ការចែកចាយ នឹង បច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួន ក្នុងការបំពេញតម្រូវការដែលកំពុងកើនឡើងនៃទីផ្សារធនាគារនៅកម្ពុជា។

ក្រុមហ៊ុន **PhillipCapital** គឺជាក្រុមសម្ព័ន្ធផ្តល់សេវាហិរញ្ញវត្ថុចំរុះដែលមានមូលដ្ឋាននៅប្រទេសសិង្ហបុរី ដោយផ្តល់នូវផលិតផល និង សេវាកម្មជាច្រើនដូចជា ជើងសារភាគហ៊ុន ហិរញ្ញវត្ថុសាជីវកម្ម ការទិញបំណុលមានអប្បបរមា ទំនិញដែលទិញដូរបច្ចុប្បន្នតែប្រគល់នៅពេលក្រោយ ឧបករណ៍ហិរញ្ញវត្ថុ ការធានារ៉ាប់រង និង ការគ្រប់គ្រងទ្រព្យសម្បត្តិក្នុងប្រទេសចំនួន ១៦ ប្រទេស។

បច្ចុប្បន្ននេះ ក្រុមហ៊ុន **PhillipCapital** មានភាគហ៊ុនសំខាន់នៅក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួនពីរនៅក្នុង ប្រទេសកម្ពុជា ពោលគឺ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត និង **First Finance** ។ យើងមានការសប្បាយចិត្តក្នុងការរាយការណ៍ថាក្រុមនេះបានទទួលការអនុម័តជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជា នៅខែធ្នូ ឆ្នាំ ២០១៥ ដើម្បីផ្តួបបញ្ចូលចូលគ្នារវាងមីក្រូហិរញ្ញវត្ថុក្រេឌីត និងធនាគារទៅក្នុងអង្គភាពតែមួយ។ បណ្តាញសាខារបស់ធនាគារនេះ នឹងត្រូវបានពង្រីកយ៉ាងទូលំទូលាយពីសាខាទាំង ៦ នៅក្នុងទីក្រុងភ្នំពេញ នាពេលបច្ចុប្បន្នទៅសាខាជាង ៩០ កន្លែងទៀតនៅទូទាំងប្រទេសបន្ទាប់ពីការផ្តួបបញ្ចូលគ្នា។ ការងាររៀបចំការរួមបញ្ចូលគ្នាបានកំពុងនឹងដំនើរការ។

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់ខ្លួន ជាពិសេសនៅក្នុងន័យភាពសុចរិត និងភាពស្មោះត្រង់ ធនាគារបានចូលរួមជាមួយអង្គការតម្លាភាពអន្តរជាតិកម្ពុជា (" TI ") នៅឆ្នាំ ២០១៥ដើម្បីជួយយើងក្នុងការផ្តល់នូវការបណ្តុះបណ្តាលដល់បុគ្គលិករបស់យើងទាំងអស់ ការកែសម្រួលគោលនយោបាយដែលមានស្រាប់របស់យើង និងការណែនាំគោលនយោបាយថ្មីដើម្បីពង្រឹងអភិបាលកិច្ចសាជីវកម្មរបស់ធនាគារ។

## សេចក្តីថ្លែងអំណរគុណ

តាងនាមជាក្រុមប្រឹក្សាភិបាល ខ្ញុំសូមយកឱកាសនេះអរគុណដល់មន្ត្រីទាំងអស់នៃធនាគារជាតិនៃកម្ពុជា សម្រាប់ការណែនាំការគាំទ្រ និង ការផ្តល់ដំបូន្មានរបស់ពួកគេជាបន្តបន្ទាប់។

យើងក៏សូមថ្លែងអំណរគុណដល់អតិថិជនរបស់យើង សម្រាប់ការជឿជាក់ និងការគាំទ្ររបស់ពួកគេ ហើយរង់ចាំបន្តការកសាងភាពជាដៃគូរឹងមាំ នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ដោយយើងនិងបន្តខិតខំកែលម្អផលិតផល និងសេវាកម្មរបស់យើង។

សមិទ្ធិផលរបស់យើងត្រូវបានរួមចំណែកផងដែរដោយការខិតខំប្រឹងប្រែង និងការប្តេជ្ញាដ៏ឥតនឿយហត់របស់បុគ្គលិករបស់យើងដែលជាធនធានដ៏មានតម្លៃ ហើយយើងក៏សូមថ្លែងអំណរគុណដល់ពួកគេផងដែរ ។

**Lim Hua Min**
ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីសង្ខេបផ្នែកហិរញ្ញវត្ថុ

| | ២០១៩ | ២០១៨ | ២០១៧ | ២០១៦ |
|---|---|---|---|---|
| **លទ្ធផលប្រតិបត្តិការ (USD$'000)** | | | | |
| ចំណូលប្រតិបត្តិការ | ៥,៥៦៨ | ៤,១៨០ | ៤,១៤៤ | ៣,០៦០ |
| (ប្រាក់ខាត) ចំណេញមុនបង់ពន្ធអាករ | (៣០០) | ២០៩ | (១២០) | (១០១) |
| (ប្រាក់ខាត) ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ | (៣៥៣) | ១៦៥ | (៣៧៩) | (១៥៦) |
| **សមតុល្យប្រចាំខែ KEY BALANCE SHEET DATE (USD$'000)** | | | | |
| ទ្រព្យសកម្មសរុប | ១០៥,៦៤៤ | ៨៤,១៣៦ | ៧០,២២៥ | ៦២,៦៦៨ |
| ឥណទាននិងបុរេប្រទាន | ៦៨,៤៨០ | ៣៧,៨១៦ | ៣៥,៩២០ | ៣១,២៧១ |
| ទ្រព្យអកម្មសរុប | ៦៦,៦៦៣ | ៤៥,៨០២ | ៣២,០៥៦ | ២៤,១១៩ |
| ប្រាក់បញ្ញើ | ៦១,៩៦០ | ៤៥,២១៨ | ៣១,៦៦៨ | ២៣,៧៧៥ |
| ដើមទុន និងទុនបម្រុងបន្ថែម | ៤១,០០០ | ៤០,០០០ | ៤០,០០០ | ៤០,០០០ |
| មូលនិធិម្ចាស់ភាគហ៊ុន | ៣៨,៩៨១ | ៣៨,៣៣៤ | ៣៨,១៦៩ | ៣៨,៥៤៩ |
| **ផលធៀបផ្នែកហិរញ្ញវត្ថុ** | | | | |
| (ប្រាក់ខាត)/ប្រាក់ចំណេញពីភាគហ៊ុននីមួយៗ (Earning per share) (គិតជាUS$) | (0.00៩) | 0.00៤ | (0.00៩) | (0.00៤) |
| ទឹកប្រាក់ទូទាត់រួចសរុបពីភាគហ៊ុននីមួយៗ | 0.៩៥ | 0.៩៦ | 0.៩៥ | 0.៩៦ |
| ប្រាក់ចំណេញសរុបពីមូលនិធិម្ចាស់ភាគហ៊ុន(%) | (0.៩១) | 0.៤៣ | (0.៩៩) | (0.៤០) |
| ប្រាក់ចំណេញពីទ្រព្យ (%) | (0.៣៣) | 0.២០ | (0.៥៤) | (0.២៥) |
| អត្រាសាច់ប្រាក់ទំនេរ (Liquidity Ratio)(%) | ៥៧.៥២ | ១២៤.៦០ | ១៣១.២៥ | ១៤៨.២៣ |
| ផលធៀបប្រាក់កម្ចីនិងប្រាក់បញ្ញើ (Loan-to-deposit ratio) (%) | ១១៣.៤២ | ៨៧.៦៩ | ១២០.០៤ | ១៣៥.៨០ |
| ផលធៀបប្រាក់កម្ចីមិនឱ្យផល និងប្រាក់ កម្ចីសរុប (Non-performing loans to total loans (%) | ១.៥៧ | ៤.១៥ | ៤.៩២ | ៤.៧៤ |
| **ការគ្រប់គ្រងប្រាក់ដើមទុន** | | | | |
| ផលតម្លៃសុទ្ធ Net worth (US$'000) | ៣៨,៤៣០ | ៣៨,៥៩៨ | ៣៨,៤៣៩ | ៣៨,៧២២ |
| ផលធៀបលទ្ធភាពសងបំណុល (Solvency ratio) (%) | ៤៥.៩៥ | ៥៩.១៦ | ៦៣.៥៥ | ៦៩.៤៤ |

# សេចក្តីសង្ខេបហិរញ្ញវត្ថុរយៈពេល៣ឆ្នាំ



## ១) ទ្រព្យសកម្មសរុប

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| លាន ដុល្លា | ៧០,២៣ | ៨៤,១៣ | ១០៥,៦៤ |




## ២) ឥណទាន និង បុរេប្រទាន

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| លាន ដុល្លា | ៣៥,៩២ | ៣៧,៨២ | ៦៨,៤៨ |



# សេចក្ដីសង្ខេបហិរញ្ញវត្ថុរយៈពេលពាឆ្នាំ (តពីទំព័រមុន)

## ៣) ប្រាក់បញ្ញើ

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| លាន ដុល្លា | ៣១,៦៧ | ៤៥,២២ | ៦១,៩៦ |




## ៤) មូលនិធិម្ចាស់ភាគហ៊ុន

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| លាន ដុល្លា | ៣៨,១៧ | ៣៨,៣៣ | ៣៨,៩៨ |



# សេចក្តីសង្ខេបហិរញ្ញវត្ថុរយៈពេល៣ឆ្នាំ ( តពីទំព័រមុន )



## ៥ ) ចំណូលប្រតិបត្តិការ

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| លាន ដុល្លា | ៤,១៤ | ៤,១៨ | ៥,៥៧ |




## ៦ ) ចំណេញ / ខាតមុនបង់ពន្ធ

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| លាន ដុល្លា | ( ០,១២ ) | ០,២១ | ( ០,៣០ ) |



# ការវិភាគលើលទ្ធផលហិរញ្ញវត្ថុ

## ចំណូលប្រតិបិត្តការ

ចំណូលប្រតិបិត្តការរបស់ធនាគារត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ មានចំនួន ៣៣,២៥% ច្រើនជាងមុន ស្មើនឹង ៥,៥៧លានដុល្លារ បើប្រៀបធៀប នឹងឆ្នាំមុនដែលមានចំនួនត្រឹមតែ ៤,១៨លានដុល្លារ ត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៤។ គុណសម្បត្តិចម្បងដែលនាំឲ្យចំណូលប្រតិបត្តិការកើនឡើង គឺដោយសារតែកំណើនចំណូលការប្រាក់ពីការផ្តល់ឥណទាន និង បុរេប្រទានជូនអតិថិជនក្នុងខណៈពេលដែលផលប័ត្រឥណទាន របស់ធនាគារកំពុងតែកើនឡើង។ ប្រភពចំណូលប្រតិបត្តិការត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៥នេះ បានពីឥណទាននិងបុរេប្រទានចំនួន ៨១,៨៧% និងការដាក់ប្រាក់បញ្ញើតាមស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ចំនួន ៥,៥៧%។

## (កំហាត)/ចំណេញមុនបង់ពន្ធអាករ និង (កំហាត)/ចំណេញក្នុងមួយហ៊ុន

ធនាគារបានខាតបង់ប្រាក់មុនពេលបង់ពន្ធចំនួន ៣ សែនដុល្លារសម្រាប់ឆ្នាំ២០១៥ ត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៥បើធៀបនឹងប្រាក់ចំនេញក្រោយបង់ពន្ធរួច ចំនួន២សែន១មុឺនដុល្លារ ក្នុងឆ្នាំ ២០១៤។ ផលធៀបរវាងចំណាយ និងចំណូល របស់ធនាគារ ប្រចាំឆ្នាំ ២០១៥ គឺទាបជាងមុនបន្តិចគឺនៅត្រឹម ០,៧០:១ បើប្រៀបធៀបនឹងឆ្នាំមុនដែលមានចំនួន ០,៧៥:១។ សមាសភាពចំណាយប្រតិបត្តិការរបស់ធនគារ នៅឆ្នាំនេះដែលស្ថិតក្រោមការត្រួតពិនិត្យមានការចំណាយលើបុគ្គលិក(៤២,៣១%) ការចំណាយលើការរំលោះសម្ភារៈ និងការរំលោះបំណុល (១៣,០៨%) ការចំណាយទាក់ទងនឹងការបង្កើតផ្សេងៗ (២២,០៥%) ការចំណាយលើការផ្សព្វផ្សាយនិងទីផ្សារ(៤,៣៦%)និងការចំនាយលើផ្នែករដ្ឋបាល និងប្រតិបត្តិការផ្សេងៗ (១៨,២០%)។

ធនាគារមានកំហាតសុទ្ធប្រចាំឆ្នាំចំនួន ៣សែន៥មុឺនដុល្លារនេះបើធៀបនឹងប្រាក់ចំណេញ ចំនួន ១សែន៦មុឺនដុល្លារក្នុងឆ្នាំ ២០១៤ ដែលបានគិតបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៤ គឺដោយសារការចំណាយប្រតិបត្តិការច្រើនជាងមុន និង ការចំណាយប្រាក់ដើមទុនខ្ពស់សម្រាប់ការប្តូរទីតាំងការិយាល័យកណ្តាលទៅកន្លែងធំជាងមុននៅបណ្តោយមហាវិថីព្រះមុនីវង្ស និងការបើកសាខាមួយទៀតក្នុងសង្កាត់ទឹកថ្លា។ ប្រាក់ខាត នៃភាគហ៊ុននីមួយៗរបស់ធនាគារ ប្រចាំឆ្នាំ ២០១៥ គឺ 0.00៩ដុល្លា នេះ បើប្រៀបនឹងប្រាក់ចំណេញពីភាគហ៊ុននីមួយៗ ដែលមានចំនួន$0.00៤ ដុល្លាកាលពីឆ្នាំមុន។

## ពន្ធ

ការបង់ពន្ធមានរាប់បញ្ចូលទាំងពន្ធលើប្រាក់ចំណូល និងពន្ធពន្យារ។ ដោយធនាគារ ទទួលបានប្រាក់ចំណេញមុនការបង់ពន្ធតិចនៅអំឡុងឆ្នាំនេះ ពន្ធលើប្រាក់ចំណូលរបស់ធនាគារគឺផ្អែកលើពន្ធអប្បបរមាចំនួន ១% នៃប្រាក់ចំណូលដោយអនុលោមតាមច្បាប់ពន្ធដារ របស់ប្រទេសកម្ពុជា។ អត្រាពន្ធដារជាមធ្យមរបស់ធនាគារ សម្រាប់ឆ្នាំនេះដែលកំពុងស្ថិតក្រោម ការត្រួតពិនិត្យគឺខ្ពស់ជាងអត្រាពន្ធកំណត់ដោយច្បាប់ចំនួន២០% ដែលបញ្ហាចម្បងគឺដោយសារ ការចំណាយជាក់លាក់ដែលមិនអាចកាត់ចេញបានសម្រាប់ការបង់ពន្ធ ហើយធនាគារគឺជាកម្មវត្ថុពន្ធអប្បបរមា។

## ទ្រព្យសកម្មសរុប

ទ្រព្យសកម្មសរុបរបស់ធនាគារ មានតម្លៃ ១០៥,៦៤លានដុល្លារ គិតត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៥ដែលជាចំនួនកើនឡើង២៥,៥៧%លើទឹកប្រាក់ឆ្នាំ២០១៤ ដែលមានចំនួន ៨៤,១៣ លាន ដុល្លារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ ទ្រព្យសកម្ម របស់ធនាគារ គឺពឹងផ្អែកជាសំខាន់លើការផ្តល់ឥនទាន និង បុរេប្រទាន ដល់អតិថិជន (៦៤,៨២%)បើប្រៀបធៀបទៅនឹងឆ្នាំមុនធនាគារ ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥ ដែលទាក់ទងគ្នាទៅនឹងឆ្នាំមុន គិតត្រឹមថ្ងៃ ទី៣១ ធ្នូ ២០១៤ គឺធ្វើឲ្យមានផលវិជ្ជមាន ដោយសារកំណើនប្រាក់បញ្ញើអតិថិជន និង ធនាគារផ្សេងៗចំនួន ៣៧% ស្ថាប័នហិរញ្ញវត្ថុ (៧,២៨%) និង សមតុល្យនៅធនាគារកណ្តាល (១៦,៧៧%)។

## ឥណទាន និង បុរេប្រទាន

ឥណទាន និង បុរេប្រទាន ជូនអតិថិជនផ្តោតសំខាន់លើការផ្តល់ឥណទានរយៈពេលវែងទៅកាន់អតិថិជន។
ឥណទាន និង បុរេប្រទានដែលផ្តល់ជូនអតិថិជនបានកើតរហូត ដល់ ៧៧,២៣% ស្មើនឹង ទឹកប្រាក់ចំនួន៧០,២៧លានដុល្លារ គិតត្រឹមថ្ងៃទី៣១ខែធ្នូ ២០១៥ បើធៀបនឹង ឆ្នាំ២០១៤ ដែលមាន ចំនួន ៣៩,៦៥ លានដុល្លារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ២០១៤។ នៅថ្ងៃទី ៣១ ខែធ្នូ ២០១៥ ផលប័ត្រឥនទានរបស់ធនាគាររួមមានការផ្តល់ ឥណទាន និងបុរេប្រទានជូនវិស័យជាច្រើននៅកម្ពុជាពិសេសវិស័យអចលនទ្រព្យ និងការជួល (២៩%) ផ្ទះ(១០,១២%) ជំនួញលក់ដុំ និងលក់រាយ(២០,៣២%) ផលិតកម្ម (៨,០៧%) កសិកម្ម (១,៨១%) និងវិស័យសណ្ឋាគារ និង ភោជនីយដ្ឋាន(៨,70%)។

## ទ្រព្យអកម្មសរុប

ទ្រព្យអកម្មសរុបរបស់ធនាគារ បានកើនដល់ ៦៦,៦៦លានដុល្លារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ២០១៥ បើធៀបនឹងឆ្នាំ ២០១៤ មានចំនួនត្រឹមតែ ៤៥,៨០លានដុល្លារគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ២០១៤ ដែលបណ្តាលមកពីការកើនឡើងនៃការដាក់ប្រាក់បញ្ញើពីសំណាក់ អតិថិជន និង ធនាគារនានាដែលបានកើនឡើងចំនួន ១៦,៧៤ លានដុល្លារ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ២០១៥។
ការដាក់ប្រាក់បញ្ញើពីសំណាក់ស្ថាប័នហិរញ្ញវត្ថុ និងអតិថិជននានានៅតែជាឆ្អឹងខ្នងដ៏សំខាន់ ដែលបានបង្កើននូវចំនួនទ្រព្យអកម្មរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ធ្នូ ២០១៥ដែលជាក់ស្តែងមានចំណែកដល់ទៅ ៩២,៩៥% (២០១៤: ៩៨,៧៣%) នៃទ្រព្យអកម្មសរុបរបស់ធនាគារ ។

## ប្រាក់បញ្ញើ:

ការដាក់ប្រាក់បញ្ញើពីសំណាក់ស្ថាប័នហិរញ្ញវត្ថុ និងអតិថិជនគិតត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៥រួមមានប្រាក់បញ្ញើមានកាលកំណត់(៧១,៨៤%) គណនីចរន្ត (២១,៩%) និងគណនីសន្សំ (៦,២៦%)។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤គណនីសំខាន់ៗនៃប្រាក់បញ្ញើ ពីស្ថាប័នហិរញ្ញវត្ថុ និងអតិថិជនគឺ គណនីប្រាក់បញ្ញើមានកាលកំណត់ដែលមានចំណែកដល់ទៅ ៦៨,៥៥% នៃចំនួនប្រាក់បញ្ញើសរុប។ការកើនឡើងនៃចំនួនប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុនិងអតិថិជនគិតត្រឹមថ្ងៃទី ៣១ ខែធ្នូឆ្នាំ២០១៥ កន្លងទៅនេះគឺដោយសារតែមានកំណើនអតិថិជនកាន់តែច្រើនជាងមុន ដែលបានមកដាក់ប្រាក់បញ្ញើរមានកាលកំណត់។

### ដើមទុនលក្ខន្តិកៈ

ដើមទុនលក្ខន្តិកៈរបស់ធនាគារ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ មានចំនួន៤១ លានដុល្លារ។ មានការបន្ថែមដើមទុន ចំនួន១លានដុល្លារទៀតទៅក្នុងធនាគារ នៅអំឡុងឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ធ្នូ ២០១៥។

### មូលនិធិម្ចាស់ភាគហ៊ុន និង ទ្រព្យសកម្មសុទ្ធក្នុងភាគហ៊ុននីមួយ។

គិតត្រឹមថ្ងៃទី៣១ ធ្នូ ២០១៥ មូលនិធិរបស់ម្ចាស់ភាគហ៊ុនបានកើនឡើងពី ៣៨,៣៣ លានដុល្លារដល់ ៣៨,៩៨ លានដុល្លារ ដែលនេះគឺជាលទ្ធផលនៃភាគហ៊ុនដើមទុនបន្ថែមនានា ក្នុង ឆ្នាំ២០១៥។ ទ្រព្យសកម្មសុទ្ធក្នុងមួយហ៊ុនរបស់ធនាគារ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូឆ្នាំ២០១៥ មានតម្លៃ 0,៩៥ដុល្លារ (២០១៤: 0,៩៦ដុល្លារ)។

### ចំណូលម្ចាស់ភាគហ៊ុន និង ចំណូលទ្រព្យសកម្ម

ធនាគារបានខាតលើមូលនិធិរបស់ម្ចាស់ភាគហ៊ុន និងទ្រព្យសកម្មគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៦។ ជាក់ស្តែង ប្រាក់ចំណេញលើមូលនិធិរបស់ម្ចាស់ភាគហ៊ុនគឺ -0,៩១% (២០១៤:0,៤៣%)ហើយប្រាក់ចំណេញលើទ្រព្យសកម្មគឺ -0,៣៣% (២០១៤:0,២0%)។ ការខាតបង់ប្រាក់ចំណេញលើមូលនិធិម្ចាស់ភាគហ៊ុនប្រចាំឆ្នាំ ២០១៤ គឺដោយសារតែធនាគារ បានជួបប្រទះកំហាតសុទ្ធប្រចាំឆ្នាំ កំណើននៃចំណាយប្រតិបត្តិការ និងចំណាយដើមទុនផងដែរ។

### ផលធៀបសាច់ប្រាក់ងាយស្រួល

ផលធៀបសាច់ប្រាក់ងាយស្រួលរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ គឺទាបជាងមុនដោយស្ថិតនៅ ៥៧,៥២%បើធៀបនឹងឆ្នាំ ២០១៤គឺ១២៤,៦១% គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ដោយសារកំណើនចំនួនប្រាក់បញ្ញើ មានកាលកំណត់ពីអតិថិជន និងក្រុមហ៊ុនផងដែរ។ ធនាគារបានអនុលោមតាមសេចក្តីប្រកាសលេខ ធ៧-0៤-២0៧ របស់ធនាគារជាតិ ដែលតម្រូវឲ្យមានអត្រាសាច់ប្រាក់ងាយស្រួលយ៉ាងតិច ៥0%។ ផលធៀបសាច់ប្រាក់ងាយស្រួលរបស់ធនាគារបង្ហាញថាធនាគារ មានសមត្ថភាពក្នុងការអនុញ្ញាតឲ្យអតិថិជនអាចដកប្រាក់ចេញពីប្រាក់បញ្ញើរបស់ខ្លួនបាន។

### ផលធៀបរវាងឥណទាន និង ប្រាក់បញ្ញើ

ផលធៀបរវាងឥណទាន និងប្រាក់បញ្ញើរបស់ធនាគារគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ គឺមានអត្រាខ្ពស់ជាងមុនគឺ១១៣,៤២% បើធៀបនឹងឆ្នាំ២០១៤ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមាន ចំនួន៨៧,៦៩% ដោយសារតែកំណើតផលបត្រឥនទាន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ជាមួយនិងតែកំណើនប្រាក់បញ្ញើពីសំណាក់អតិថិជន និងក្រុមហ៊ុនផងដែរ។

### ឥណទានមិនដំណើរការធៀប នឹង ឥណទានសរុប (%)

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឥនទានមិនដំណើរការ( ខូច )ត្រូវបានថយចុះយ៉ាងច្រើននៅត្រឹម ១,៥៧%បើធៀបនឹងឆ្នាំ២០១៤ មានចំនួន ៤,១៥%គិតត្រឹម ថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៤។ សំវិធានធនជាក់លាក់លើឥណទាន និងបុរេប្រទានមានការថយចុះនៅត្រឹម១១១,លានដុល្លាគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ បើធៀបនឹងឆ្នាំ២០១៤ មានចំនួនដល់ទៅ ១,៤៦លាន ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥។ ឥណទានមិនដំណើរការ (ខូច) ភាគច្រើនមានការធានាយ៉ាងល្អហើយ ធនាគារកំពុងតែដំណើរ ការស្រោចស្រង់ឥណទានទាំងនោះមកវិញ។

### មូលនិធិផ្ទាល់សុទ្ធ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារមានចំនួន៣៨,៤៣ លាន ដុល្លារ (២០១៤: ៣៨,៦0 លានដុល្លារ)ដែលជាទឹកប្រាក់លើសពីប្រាក់ដើមទុនអប្បបរមា ដែលបានកំណត់ដែលមានចំនួន ៣៧,៥0 លានដុល្លារ។ការថយចុះនេះគឺ ដោយសារតែការកើនឡើងនូវសំវិធានធនទៅលើឥណទាន និងកំហាតទៅលើប្រត្តិបត្តិការនៅក្នុងឆ្នាំ ២០១៥។

### ផលធៀបសាធនភាព

ផលធៀបសាធនភាពផ្តល់នូវការវាស់ស្ទង់នូវមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ ជាភាគរយ នៃកម្រិតហានិភ័យឥណទាន។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ ផលធៀបសាធនភាពរបស់ធនាគារ មានចំនួន ៤៥,៩៥% (២០១៤:៥៩,១៦%) ដោយអនុលោមតាមប្រកាសលេខ ធ៧-0៤-២0៧ដលៃតម្រូវឲ្យផលធៀបសាធនភាពមានយ៉ាងតិចណាស់១៥%។ ផលធៀបសាធនភាពគិតត្រឹមថ្ងៃទី ៣១ ធ្នូ២០១៥ គឺ ទាបជាងមុនដាយសារតកំណើនឥណទាននិងបុលប្រទានដល់អតិថិជនបូករួមនឹងឥណទាន និងបុរប្រទានដែលពុំទាន់ដក នៅមានកម្រិតខ្ពស់គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥។

# រចនាសម្ព័ន្ធរបស់ធនាគារ



# ប្រវត្តិរូបក្រុមប្រឹក្សាភិបាល



## MR. LIM HUA MIN
ប្រធានក្រុមប្រឹក្សាភិបាល

លោក Lim Hua Min ជាប្រធានប្រតិបត្តិនៃក្រុមហ៊ុន Phillip Capital Group ត្រូវបានតែងតាំងជាប្រធាននៃ IFS Capital លីមីធីត នៅថ្ងៃទី ២០ខែឧសភា ឆ្នាំ២០០៣។ លោកបានចាប់ផ្តើមអាជីពរបស់គាត់ដោយកាន់មុខតំណែងជាន់ខ្ពស់នៅក្នុងផ្សារហ៊ុនប្រទេសសិង្ហបុរី និងវិទ្យាស្ថានស្រាវជ្រាវមូលបត្រ។ លោកបានបំរើការជាច្រើននៅក្នុងគណៈកម្មាធិការ និងគណៈកម្មាធិការរងជាច្រើននៃផ្សារហ៊ុនរបស់ប្រទេសសិង្ហបុរី។ នៅឆ្នាំ ១៩៩៧ គាត់ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការត្រួតពិនិត្យផ្សារហ៊ុនរបស់ប្រទេសសិង្ហបុរី (SES) ដែលមានភារៈទទួលខុសត្រូវចំពោះការធ្វើក្របខ័ណ្ឌទស្សនទានមួយចំនួនដើម្បីធ្វើឲទីផ្សារមូលធនរបស់សិង្ហបុរីកាន់តែមានភាពជាសកល និងមានភាពប្រកួតប្រជែងនិងរឹងមាំ។ សម្រាប់មុខតំណែងនេះគាត់ទទួលបានរង្វាន់មេដាយសេវាសាធារណៈ (PBM) នៅឆ្នាំ ១៩៩៩ ពីរដ្ឋាភិបាលសិង្ហបុរី។ លោកបានបម្រើការជាសមាជិកក្រុមប្រឹក្សាភិបាលមួយនៅក្នុងអាជ្ញាធរប្រាក់ចំណូលជាតិរបស់ប្រទេសសិង្ហបុរីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១០ ។ លោក Lim បានទទួលបរិញ្ញាបត្រវិទ្យាសាស្ត្រ (កិត្តយស) ជំនាញវិស្វកម្មគីមីពីសាកលវិទ្យាល័យ Surrey និងការទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រតិបត្តិការគ្រប់គ្រងការសិក្សាស្រាវជ្រាវពី Imperial College, សាកលវិទ្យាល័យក្រុងឡុងដ៍។



## MR. KOH YONG GUAN
អភិបាលឯករាជ្យ

លោក Koh Yong Guan បានចូលបំរើការនៅក្នុងផ្នែកសេវាកម្មស៊ីវិលរបស់ប្រទេសសិង្ហបុរី ក្នុងនាមជាវិស្វករជីវវេជ្ជសាស្ត្រនៃក្រសួងសុខាភិបាលនៅឆ្នាំ ១៩៧២ និងបានចូលទៅបំរើការងារក្នុងសេវារដ្ឋបាលនៅឆ្នាំ១៩៧៩។ លោកបានបំរើការក្នុងក្រសួងហិរញ្ញវត្ថុ (នាយកដ្ឋានប្រាក់ចំណូល), អប់រំនិងការពារជាតិមុនពេលត្រូវបានតែងតាំងជាលេខាធិការអចិន្ត្រៃយ៍នៅក្រសួងការពារជាតិនៅឆ្នាំ ១៩៨៩។

លោក Koh ត្រូវបានតែងតាំងជាស្នងការនៃគណៈកម្មាធិការប្រាក់ចំណូលផ្ទៃក្នុងពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៧។ នៅឆ្នាំ ១៩៩៨ លោកត្រូវបានតែងតាង ជានាយកអាជ្ញាធររូបិយវត្ថុសិង្ហបុរី (ទេសាភិបាលធនាគារកណ្តាល)។ លោកក៏បានកាន់មុខដំណែងជាលេខាអចិន្ត្រៃយ៍ក្រសួងអភិវឌ្ឍន៍ជាតិសុខាភិបាល និងជាលេខាធិការអចិន្ត្រៃយ៍ទីពីរនៃក្រសួងហិរញ្ញវត្ថុ (ថវិកានិងប្រាក់ចំណូល) រវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០១។ លោកបានចូលនិវត្តន៍ពីនាយកអាជ្ញាធររូបិយវត្ថុសិង្ហបុរី(MAS) នៅខែមិថុនា ឆ្នាំ២០០៥ និងហើយនៅរក្សាសមាជិកភាពជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ MAS រហូតដល់ខែមេសាឆ្នាំ២០១១។ លោកបានបម្រើការជាប្រធានក្រុមប្រឹក្សាភិបាលកណ្តាលមូលនិធិ ក្រុមហ៊ុនផ្តល់សេវាកម្មមូលនិធិសោធន៍និវត្តន៍ជាតិសម្រាប់កម្មករនិយោជិតទាំងអស់ទាំងនៅក្នុងវិស័យឯកជននិងវិស័យសាធារណៈនៅក្នុងប្រទេសសិង្ហបុរីពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១៣។ គាត់គឺជាឧត្តមស្នងការអនិវេសន៍ជនរបស់សឹង្ហបុរីប្រចាំប្រទេសកាណាដា ចាប់ពី ខែ ឧសភា ឆ្នាំ២០០៨ ដល់ ខែ មីនា ឆ្នាំ២០១៣។ បច្ចុប្បន្ននេះលោក Koh ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនសាជីវកម្ម SMRT Ltd ជាក្រុមហ៊ុនដែលបានចុះបញ្ជីការជាសាធារណៈដែលដំណើរការប្រព័ន្ធរថភ្លើងក្រោមដី, រថយន្តក្រុង និងរថយន្តតាក់ស៊ីបំរើសេវាកម្មនៅក្នុងប្រទេសសិង្ហបុរី។ លោកក៏ជាប្រធានសាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើសឹង្ហបុរីនិងជាប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រជំងឺមហារីកនៃប្រទេសសិង្ហបុរី។

លោក Koh ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូត (អនិវេសន៍ជននៅសឹង្ហបុរី) ប្រចាំប្រទេសក្រិ ចចាប់តាំងពីខែ ឧសភា ឆ្នាំ២០១៣។ លោកបានបញ្ចប់បរិញ្ញាប័ត្រ ផ្នែកវិទ្យាសាស្ត្រអនុវត្ត (កត្តិយស) សញ្ញាបត្រផ្នែកវិស្វកម្មម៉ាស៊ីន នៅឆ្នាំ១៩៧០ និង អនុបណ្ឌិតវិទ្យាសាស្ត្រអនុវត្តនៅតាមវិស្វកម្មម៉ាស៊ីន និងវិស្វកម្មជីវវេជ្ជសាស្ត្រក្នុងឆ្នាំ១៩៧២ ពីសាកលវិទ្យាល័យតូរ៉ុនតូតាមរយៈកម្មវិធីអាហារូបករណ៍កូឡំបូ។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (ដោយមានការវិភាគវែកញែកពីសាកលវិទ្យាល័យកាតូលិកនៃ Leuven ប្រទេសបែលហ្ស៊ិកនៅឆ្នាំ ១៩៨១ លោកត្រូវបានប្រគល់ជាបណ្ឌិតកិត្តិយសដោយសាកលវិទ្យាល័យតូរ៉ុនតូនៅឆ្នាំ ២០១១។



## MR. ONG TEONG HOON
អភិបាលប្រឹក្សា

លោក Ong Teong Hoon បានចាប់ផ្តើមការងារនៅក្នុងផ្នែកហិរញ្ញវត្ថុនាឆ្នាំ១៩៧៧ ដែលការងារដំបូង របស់លោកគឺជា ឈ្មួញកណ្តាលផ្នែករូបិយប័ណ្ណមួយឆ្នាំបន្ទាប់មកគាត់បានចូលបម្រើការងារនៅក្នុងធនាគារ Standard Chartered ក្នុងមុខដំណែងជាអ្នកគ្រប់គ្រងផ្នែកបណ្តុះបណ្តាល។
ក្នុងរយៈកាល២៥ឆ្នាំក្នុងការបំពេញការងារក្នុងវិស័យធនាគារគាត់បានឆ្លងកាត់រាល់ទំរង់នៃធនាគារពាណិជ្ជដោយឡែកពីមុខងារក្នុងវិស័យរតនាគារ។ បន្ទាប់ពីនេះគាត់បានបញ្ចប់មុខដំណែងនៅក្នុងវិស័យធនាគារក្រោមតំណែងជាអ្នកគ្រប់គ្រងធនាគារប្រចាំប្រទេសនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ២០០២។

បន្ទាប់ពីកាន់កាប់មុខតំណែងជាតំណាងអគន្តាយកនៃធនាគារនៅក្នុងប្រទេសមីយ៉ាន់ម៉ា អ្នកគ្រប់គ្រងប្រចាំតំបន់, វិទ្យាស្ថានហិរញ្ញវត្ថុប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច ។ គាត់បានចូលបំរើការងារនៅក្នុងក្រុមហ៊ុន Phillip Securities Pte Ltd ដោយកាន់កាប់ការងារមួយចំនួនទៀតដូចជាបំពេញការងារមួយរយៈពេលខ្លីនៅក្នុងផ្សារមូលប័ត្រ Phillip PLC នៅក្នុងប្រទេសថៃក្នុងតំណែងជាអ្នកចាត់ការទូទៅ និងចុក្រោយជាអ្នកគ្រប់គ្រងផ្សារហ៊ុនមុននិងត្រូវបានចាត់មកអោយបំពេញការងារនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ភីអិលស៊ី ក្នុងឆ្នាំ២០១២។

លោក Ong បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យសិង្ហបុរីហើយក៏ជាសហការីនៅក្នុងវិទ្យាស្ថាន Chartered សម្រាប់វិស័យធនាគារ តាំងពីឆ្នាំ១៩៧៨ មក។

# ប្រវត្តិរូបក្រុមប្រឹក្សាភិបាល



**MR. CHAN MACH**
អភិបាលប្រឹក្សា

លោក MACH បានបំរើការងារជា CEO ដំបូងគេក្នុងគ្រឹះស្ថានហិរញ្ញវត្ថុក្រេឌីត (KREDIT) មុនពេលដែលគាត់ត្រូវបានតំឡើងតំណែងជានាយកផ្នែកប្រតិបតតិក្នុងឆ្នាំ២០០៦។ ជាមួយនិងបរិញ្ញាបត្រគណិតវិទ្យា មានបទពិសោធន៍ជាសាស្ត្រាចារ្យគណិតវិទ្យា លោក Mach បានចូលបំរើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត (KREDIT) នាអំឡុងឆ្នាំ១៩៩៩ ក្នុងឋានៈជាសវនករ និងជាគ្រូបង្ហាត់។ សមតភ្ថាពដ៏បិនប្រសព្វក្នុងការគ្រប់គ្រងដ៏មានសក្តានុពលរបស់លោកត្រូវបានគេទទួលស្គាល់រហូតបានទទួលការងារជាអ្នកគ្រប់គ្រងប្រចាំសាខារាជធានីភ្នំពេញ។ គាត់បានធ្វើអោយសាខានោះមានភាពរីកចម្រើនក្រោមការគ្រប់គ្រងរបស់គាត់ ហើយនៅក្នុងឆ្នាំ២០០៣គាត់ត្រូវបានគេតែងតាំងជានាយកផ្នែកប្រតិបត្តិ ក្រោមការដឹកនាំគ្រប់គ្រងរបស់គាត់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត (KREDIT) បានប្រែក្លាយទៅជាគ្រឹះស្ថានដ៏មានស្ថេរភាពមួយនិងទទួលបានផលចំណេញត្រីគុណ។ លោកបានទទួលបរិញ្ញាបត្រ ជាន់ខ្ពស់ចំនួន២ គឺ MBA និង MFB។ ជាមួយគ្នានេះផងដែរគាត់បានទទួលការបណ្តុះបណ្តាលទាក់ទងទៅនឹងផ្នែកមីក្រូហិរញ្ញវត្ថុ និងធនាគារទាំងលក្ខណៈជាតិ និងអន្តរជាតិ។



**MS. DIANA SEAH YEN GOON**
អភិបាលឯករាជ្យ

Diana Seah Yen Goon មានបទពិសោធន៍ច្រើនជាង 30 ឆ្នាំនៅក្នុងស្ថាប័នហិរញ្ញវត្ថុរួមទាំងក្រុមហ៊ុនហិរញ្ញវត្ថុពាណិជ្ជ GE ដែលមានជំនាញក្នុងការផ្តល់ហិរញ្ញប្បទានសហគ្រាសខ្នាតតូចនិងមធ្យម។ លោកស្រីបានកាន់តំណែងជាន់ខ្ពស់ក្នុងផ្នែកហិរញ្ញវត្ថុប្រតិបត្តិការ, ព័ត៌មានវិទ្យា, ត្រួតពិនិត្យមើលប្រតិបត្តិការនៅប្រទេសសិង្ហបុរី ថៃនិងហុងកុង។ លោកស្រីធ្លាប់ជាប្រធានការិយាល័យហិរញ្ញវត្ថុ ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុនិងអភិបាលកិច្ច, ធ្វើផែនការយុទ្ធសាស្ត្រនិងហិរញ្ញវត្ថុការផ្តល់មូលនិធិនិងការអនុលោមតាមច្បាប់។ លោកស្រីបានធ្វើការបណ្តុះបណ្តាលសិក្ខាសាលានៅមហាវិទ្យាល័យ Civil Service និងបម្រើការនៅអនុគណៈកម្មាធិការធនធានមនុស្ស នៃមន្ទីរពេទ្យ St.Luke និង ផ្ទះសម្រាប់គ្រឹះសាសនិកនៃប្រទេសសឹង្ហបុរី។

លោកស្រីDiana Seah ជាគណនេយ្យករ (សឋិប្តុរី) ដែលទទួលបានបរិញ្ញាបត្រ គណនេយ្យពីសាកលវិទ្យាល័យប្រទេសសិង្ហបុរី, ឥឡូវនេះបានប្តូរឈ្មោះជាសាកលវិទ្យាល័យជាតិសិង្ហបុរី និង សញ្ញាបត្រអនុបណ្ឌិត (ច្បាប់ពាណិជ្ជសាស្ត្រ ពីសាកលវិទ្យាល័យបច្ចេកវិទ្យា Nanyang។



**MR. MICHAEL TAN**
អភិបាលប្រឹក្សា

បច្ចុប្បន្ននេះលោក Michael Tan គឺជានាយកការិយាល័យសាជីវកម្មនៅក្រុមហ៊ុន Phillip Capital ។ មុនពេលចូលរួមជាមួយក្រុមហ៊ុន Phillip Capital, កាលពីមុនលោកបានកាន់តំណែងទាំងក្នុងវិស័យឧស្សាហកម្ម និង អប់រំរួមទាំង បំពេញភារកិច្ចជាជំនួយការសាស្ត្រចារ្យនៅឯសាកលវិទ្យាល័យនៃរដ្ឋ Nevada, ទីក្រុង Reno សហរដ្ឋអាមេរិក, ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យជាតិសិង្ហបុរី, ជាអ្នកគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា និងតំណែងជាអ្នកប្រឹក្សាយោបលនៅប្រទេសសិង្ហបុរី។ លោកបានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកប្រពន័ព្ធត័មានវិទ្យាពីសាកលវិទ្យាល័យជាតិសិង្ហបុរី, ទទួលបានវិញ្ញាបនប័ត្រ SAP Consultant (ប្រព័ន្ធគម្រោង), វិញ្ញាបនបត្រ័ SAP ពីប្រទេសអាលល្មឺង់, CDipAF (គណនេយ្យនិងហិរញ្ញវត្ថុដែលជាការបណ្តុះបណ្តាលពី ACCA (ប្រទេសអង់គ្លេស) និងក៏បានជាប់ម៉ូឌុល CMFASនានាដែលគ្រប់គ្រងដោយ IBF (ប្រទេសសិង្ហបុរី) និងក្រុមហ៊ុន SCI (ប្រទេ សសិង្ហបុរី) ។



**MR. PAUL GWEE CHOON GUAN**
អភិបាលឯករាជ្យ

លោក Paul Gwee Choon Guan បានបំពេញការងារផ្នែកធនាគារជិត២៥ឆ្នាំមកហើយ លោកមានបទពិសោធន៍ច្រើនក្នុងផ្នែក សាកល និងរតនាគារ/ ធនាគារវិនិយោគជាមួយនឹងការគ្រប់គ្រងទុនមូលនិធិ និងទ្រព្យសម្បត្តិនៅទូទាំង តំបន់អាស៊ីប៉ាស៊ីហ្វិច ។ គាត់មានជំនាញឯកទេសលើផ្នែកមួយចំនួនដូចជា វិស័យគ្រប់គ្រងហានិភ័យសហគ្រាស (ឥណទាន, ទីផ្សារ,លំហូរសាច់ប្រាក់ និងប្រតិបត្តិការ) ការត្រួតពិនិត្យនិងអនុវត្តនៃការរួមបញ្ចូលគ្នាវិញនូវការប្រតិបត្តិការក្រៅឆាកជាមួយ និងយុទ្ធសាស្ត្រផ្នែក អាជីវកម្ម និង ផ្នែកហរិញ្ញវត្ថុធ្វើរបាយការណ៍អាជីវកម្មគណនេយ្យ, ការច្របាច់បញ្ចូលគ្នា និងការទិញយកភាគហ៊ុន និងការគ្រប់គ្រងមូលធន។ គាត់ជាអតីតនាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាមនៃធនាគារ United Overseas Bank Group បន្ទាប់មកជាប្រធានហរិញ្ញវត្ថុទីក្រុងហុងកុង និងធនាគារស៊ាងហៃ , ប្រទេសឥណ្ឌូនេស៊ីនិងជាប្រធាននាយកប្រតិបត្តិនៅក្នុងធនាគារនៃអាស៊ីខាងកើតនៅប្រទេសសិង្ហបុរី។ បច្ចុប្បន្នលោកជាអគ្គលេខាធិការនៃសមាគមធនាគារអាស៊ាន។ លោក Gwee បានទទួលអនុបណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យឈីកហ្គោហើយបានបញ្ចប់ការសិក្សាពីសាលា ពាណិជ្ជសាស្ត្រ លើជំនាញហិរញ្ញវត្ថុ និងបានទទួលបរិញ្ញាបត្រពាណិជ្ជសាស្ត្រពីសាកលវិទ្យាល័យ Newcastle ។ លោកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាគណនេយ្យករក្នុងឆ្នាំ១៩៨៤ និង ជាសមាជិក នៃវិទ្យាស្ថាន Chartered Accountantsក្នុងប្រទេសអូស្ត្រាលី និង វិទ្យាស្ថាន Chartered Accountants នៃប្រទេសសិង្ហបុរី ។




**លោក ហាន ប៉េងគាន់**
**អគ្គនាយក**

ហាន បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យភាគខាងជើងម៉ាឡេស៊ី ក្នុងឆ្នាំ១៩៩៥ ហើយគាត់ក៏ទទួលបានវិញ្ញាបនបត្រ វិជ្ជាជីវៈផ្នែកឥណទាន ពីវិទ្យាស្ថានធនាគារម៉ាឡេស៊ីផងដែរ។

មានបទពិសោធន៍ផ្នែកធនាគារជាង១៩ឆ្នាំ ដោយបានចាប់ផ្តើមការងារពីឆ្នាំ១៩៩៤ ក្នុងពេលដែលគាត់បានបម្រើការងារជាមួយធនាគារសាធារណៈបឺហេដ ដែលជាធនាគារមានឈ្មោះល្បីមួយនៅប្រទេសម៉ាឡេស៊ី ក្នុងតួនាទីជាអ្នកហាត់ការ បន្ទាប់មកត្រូវបានតម្លើងឋានៈជាបន្តបន្ទាប់រហូតក្លាយជាប្រធានសាខា។ បទពិសោធន៍ផ្នែកធនាគាររបស់គាត់រួមមាន ប្រតិបត្តិការជួរមុខ ទីផ្សារ ដំណើការឥណទាន មូលបត្រប្រាក់កម្ចី និងឯកសារត្រួតពិនិត្យឥណទាន ត្រួតពិនិត្យបំណុល និងពាណិជ្ជកម្មហិរញ្ញវត្ថុ។

បានចូលបម្រើការងារនៅធនាគារ ហ្វង ឌីប៊ីអេស (ដែលបច្ចុប្បន្ននេះជា ធនាគារ ហ្វីលីព) ចាប់តាំងពីធនាគារបើកដំណើការដំបូងក្នុងឆ្នាំ២០០៩រហូតដល់បច្ចុប្បន្នក្នុងតួនាទីជាអនុប្រធានជាន់ខ្ពស់ បន្ទាប់មកត្រូវបានផ្លាស់ប្តូរមុខតំណែងជាអគ្គនាយកក្នុងឆ្នាំ២០១១។ គាត់ទទួលខុសត្រូវទៅលើប្រតិបត្តិការទាំងស្រុងរបស់ធនាគារ ហើយបានពង្រីកបណ្តាញធនាគារពីមួយសាខាក្នុងឆ្នាំ២០០៩ រហូតដល់ប្រាំមួយសាខា។ គាត់នៅតែបន្តកាន់តួនាទីជាអគ្គនាយកធនាគារ ហ្វីលីព បន្ទាប់ពីមានការផ្លាស់ប្តូរម្ចាស់ភាគហ៊ុននៅឆ្នាំ២០១៤។




**លោក អ៊ាត ចិត្រាសូរិវង្ស**
**នាយកដ្ឋានព័ត៍មានវិទ្យា**

សូរិវង្ស បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យាពីសាកលវិទ្យាល័យ ន័រតុន។ គាត់បានបញ្ចប់វគ្គបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងវិស័យធនាគារ ទាំងការបណ្តុះបណ្តាលថ្នាក់ជាតិ និងអន្តរជាតិ។

សូរិវង្ស មានបទពិសោធន៍ជាង១០ឆ្នាំពាក់ព័ន្ធផ្នែកព័ត៌មានវិទ្យា ជាពិសេសជាមួយវិស័យធនាគារ។ គាត់ធ្លាប់បានបំពេញការងារជាមួយធនាគារពាណិជ្ជធំៗចំនួនបួន ហើយគាត់បានបំពេញតួនាទីជាបុគ្គលិកបច្ចេកទេស និងអ្នកគ្រប់គ្រងជាច្រើនលើកដូចជា ប្រធានផ្នែកព័ត៌មានវិទ្យានៅធនាគារមេយប៉ែងកម្ពុជា ប្រធានផ្នែកព័ត៌មានវិទ្យានៅធនាគារ ហ្វងឌីប៊ីអេស ភីអិលស៊ី (បច្ចុប្បន្នត្រូវបានគេស្គាល់ថាជាធនាគារ ហ្វីលីព) ធនាគារអង្គរកាប់ពីតាល់ (បច្ចុប្បន្នជាធនាគារឯកទេសអង្គរកាប់ពីតាល់) ក៏ដូចជាបុគ្គលិកគ្រប់គ្រងប្រព័ន្ធ/ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ មន្ត្រីរដ្ឋបាលប្រព័ន្ធ និង ព័ត៌មានវិទ្យា នៅធនាគារកម្ពុជា សាធារណៈ។

ក្នុងចំណោមធនាគារពាណិជ្ជទាំងបួននេះ គាត់ក៏ជាសហស្ថាបនិកម្នាក់ដែលបានអនុវត្តប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធនៅធនាគារចំនួនពីរនៅប្រទេសកម្ពុជា។ បទពិសោធន៍ជាមួយវិស័យធនាគាររបស់គាត់រួមមានការកំណត់អត្តសញ្ញាណនិងអនុវត្តដំណោះស្រាយបច្ចេកវិទ្យាព័ត៌មានស្របតាមតម្រូវការអាជីវកម្ម ឧទាហរណ៍ ប្រព័ន្ធធនាគារស្នូល ម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ ការគ្រប់គ្រងកាត (កាតម៉ាស្ទ័រ/កាតវីសា) ធនាគារឌីជីថលផែនការស្តារមហន្តរាយ បង្កើតហេដ្ឋារចនាសម្ព័ន្ធតាមសាខា ក៏ដូចជាប្រព័ន្ធ សុវត្ថិភាពនៅតាមសាខា ប្រព័ន្ធប្រតិបត្តិការ/ការធ្វើតេស្តហេដ្ឋារចនាសម្ព័ន្ធ បង្កើត/អភិវឌ្ឍគោលនយោបាយ / នីតិវិធីព័ត៌មានវិទ្យា និងផែនការយុទ្ធសាស្ត្រព័ត៌មានវិទ្យា។

សូរិវង្ស បានចូលបម្រើការងារនៅធនាគារហ្វីលីព ក្នុងខែកញ្ញា ឆ្នាំ២០១៣ ក្នុងតួនាទីជាប្រធាននាយក ដ្ឋានព័ត៌មានវិទ្យា។




**លោក ហូរ ប៉យលាង**
**នាយកដ្ឋានហានិភ័យឥណទាន**

ជេនសេនហូរ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពីសាកលវិទ្យាល័យ វីនស័រ ប្រទេសកាណាដាក្នុងឆ្នាំ១៩៨៤ និងបានប្រឡងជាប់វិញ្ញាបនបត្រវិជ្ជាជីវៈឥណទាន ពីវិទ្យាស្ថានធនាគារម៉ាឡេស៊ីក្នុងឆ្នាំ២០០៤។

គាត់មានបទពិសោធន៍ជាមួយវិស័យធនាគារជាង៣០ឆ្នាំ ចាប់ពីឆ្នាំ១៩៨៥ដោយគាត់បានចូលបម្រើការងារនៅធនាគារសាធារណៈ ប៊ីហេដ ក្នុងតួនាទីជាបុគ្គលិកហាត់ការ បន្ទាប់មកត្រូវបានតម្លើងឋានៈជាបន្តបន្ទាប់រហូតក្លាយជាប្រធានសាខាធនាគារក្នុងឆ្នាំ១៩៩១។
បទពិសោធន៍របស់គាត់រួមមានដូចជា៖ ផ្នែកប្រតិបត្តិការ ផ្នែកទីផ្សារ ផ្នែកដំណើរការឥណទាន ផ្នែករៀបចំឯកសារមូលប័ត្រប្រាក់កម្ចី ផ្នែក រដ្ឋបាលឥណទាន ផ្នែកគ្រប់គ្រងបំណុលនិងផ្នែកពាណិជ្ជកម្មហិរញ្ញវត្ថុ។

ក្នុងឆ្នាំ២០០១ គាត់បានចូលបម្រើការងារនៅធនាគារ មេយប៊ែង ម៉ាឡេស៊ី ដោយទទួលភារកិច្ចជាប្រធានផ្នែកឥណទានបុគ្គល និងអាជីវកម្មបន្ទាប់មកក៏ត្រូវបានតែងតាំងជា ប្រធានអភិវឌ្ឍអាជីវកម្មនៅធនាគារមេយប៊ែងប្រទេសកម្ពុជាក្នុងឆ្នាំ២០១០ ដោយគាត់ទទួលភារកិច្ចដំណើរការឥណទានជាក្រុម និងឥណទានអាជីវកម្មពីសាខាអន្តរជាតិជាច្រើន។ នៅខែមករា ឆ្នាំ២០១៥ គាត់បានចូលបម្រើការងារនៅធនាគារ ហ្វីលីព ភីអិលស៊ី ក្នុងតួនាទីជាប្រធានផ្នែកហានិភ័យឥណទាន ជាមួយវត្ថុបំណងជម្រុញការរីកចម្រើនឥណទានជូនធនាគារ និងធ្វើអោយមានភាពប្រសើរឡើងនូវបទដ្ឋាននៃដំណើរការឥណទានដើម្បីសម្រេចបាននូវគោលដៅប្រាក់ចំណេញសម្រាប់ធនាគារ។




**លោក សឿង ភីរី**
**នាយកដ្ឋាន ហានិភ័យនិងប្រតិបត្តិ**

ភីរី បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពីវិទ្យាស្ថានជាតិគ្រប់គ្រង និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យឆាលស្ទើត ។

ភីរី មានបទពិសោធន៍ច្រើនពាក់ព័ន្ធផ្នែកហានិភ័យ ប្រតិបត្តិ និងហិរញ្ញវត្ថុ រួមទាំងតួនាទីជានាយកហានិភ័យ និងប្រតិបត្តិ នៅស្ថាប័នមីក្រូហិរញ្ញវត្ថុ អេអឹមខេ ប្រធានប្រតិបត្តិហានិភ័យ នៅ វីង ប្រធានត្រួតពិនិត្យផ្ទៃក្នុង និងប្រតិបត្តិ, ទីប្រឹក្សាគ្រប់គ្រងហានិភ័យ និងសវនករប្រចាំប្រទេស នៅអង្គការភ្លែនកម្ពុជា សវនករ ជាន់ខ្ពស់ផ្នែកប្រតិបត្តិការ និងសវនករហិរញ្ញវត្ថុ នៅអង្គការទស្សនៈពិភពលោកកម្ពុជា  ព្រមទាំងជា គណនេយ្យករ និងរដ្ឋបាលនៅអង្គការមិត្តសម្លាញ់។
ភីរី បានចូលបម្រើការងារជាមួយ ធនាគារ ហ្វីលីព តួនាទីជា ប្រធាន ហានិភ័យ និងប្រតិបត្តិក្នុងខែកុម្ភៈ ឆ្នាំ២០១៣។




**លោក ដូមីនិក តែវ ជូ បេង** (DOMINIC TEO CHWEE BENG)
**នាយកដ្ឋានប្រតិបត្តិការ**

ដូមីនិក បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងផ្នែកធនាគារ និងហិរញ្ញវត្ថុពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុប្រទេសសិង្ហបុរី។

ដូមីនិក មានបទពិសោធន៍ខាងធនាគារជាង៣០ឆ្នាំ ក្នុងផ្នែកប្រតិបត្តិការ ផ្នែកគ្រប់គ្រងហានិភ័យ ក៏ដូចជាផ្នែកសវនកម្មផ្ទៃក្នុងជាមួយធនាគារ ស្តែនដាតឆាតទ័រ ប្រទេសសិង្ហបុរី។ គាត់បានបំពេញការងារជាមួយក្រុមសវនករ ឌីប៊ីអេស មួយរយៈដើម្បីធ្វើសវនកម្មលើផ្នែកប្រតិបត្តិការនិងបច្ចេកវិទ្យាធនាគារ។ គាត់បានចាប់ផ្តើមការងារដំបូងជាបុគ្គលិកស្មៀន បន្ទាប់មកជាគណៈគ្រប់គ្រងថ្នាក់កណ្តាលនៅធនាគារ ស្តែនដាត ឆាតទ័រ ប្រទេសសិង្ហបុរី ។

ដូមីនិក បានចាប់ផ្តើមការងារជាមួយធនាគារ ហ្វីលីព នៅខែសីហាឆ្នាំ២០១៤ ក្នុងតួនាទីជាប្រធាននាយកដ្ឋានប្រតិបត្តិការ។




**អ្នកស្រី ពៅ សុភ័ក្ត្រ**
**នាយកដ្ឋានធនធានមនុស្ស**

សុភ័ក្ត្រ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងទេសចរណ៍ និងសណ្ឋាគារពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងថ្នាក់បរិញ្ញាបត្ររងគ្រូបង្រៀនពី មជ្ឈមណ្ឌលគរុកោសល្យភ្នំពេញ ។

គាត់បានចាប់ផ្តើមការងារដំបូងនៅឆ្នាំ១៩៩៩ ជាគ្រូបង្រៀន ក្រោយមកជាមន្ត្រីប្រតិបត្តិធនធានមនុស្សជាមួយវិស័យឯកជន បន្ទាប់ពីបម្រើការងារជាមន្ត្រីរាជការអស់រយៈពេល ០៨ឆ្នាំ។ ក្នុងតួនាទីជាមន្ត្រីធនធានមនុស្ស គាត់បានចូលរួមជាមួយវិស័យផ្សេងៗដូចជា សេវាកម្មអាហារ និងភេសជ្ជៈ សេវាកម្ម អ៊ិនធឺណេត និងធនាគារ។

សុភ័ក្ត្រ បានចូលបម្រើការងារនៅធនាគារ ហ្វីលីព ភីអិលស៊ី ក្នុងខែមករា ឆ្នាំ២០១៣ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ធនធានមនុស្ស បន្ទាប់មកត្រូវបានតម្លើងតួនាទីជាប្រធាននាយកដ្ឋានធនធានមនុស្ស។




**លោក យុន រ៉េត**
**នាយកដ្ឋានរដ្ឋបាល**

រ៉េត បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកភាសាអង់គ្លេស ពីសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ក្នុងឆ្នាំ២០១០ ហើយបច្ចុប្បន្នកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យន័រតុន។ ដោយសារការខិតខំប្រឹងប្រែង និងឆន្ទៈ បានធ្វើអោយ រ៉េត អាចអភិវឌ្ឍខ្លួនពីតួនាទីជាសន្តិសុខ ទៅជាជំនួយការរដ្ឋបាល និងហិរញ្ញវត្ថុ បន្ទាប់មកជាមន្ត្រីរដ្ឋបាលនៅធនាគារ ភ្នំពេញពាណិជ្ជ ក្នុងរយៈពេល ០៧ឆ្នាំ។

រ៉េត បានចូលបម្រើការងារនៅធនាគារ ហ្វីលីព ភីអិលស៊ី ក្នុងខែកញ្ញាត ឆ្នាំ២០១២ក្នុងតួនាទីជាមន្ត្រីរដ្ឋបាល បន្ទាប់មកត្រូវបានតម្លើងតួនាទីជាប្រធាននាយកដ្ឋានរដ្ឋបាល។




**អ្នកស្រី ស្រ៊ន ស្រីនាង**
**នាយកដ្ឋានហិរញ្ញវត្ថុ និងរតនាគា**

ស្រីនាង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យពីសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចឆ្នាំ២០០៦ ហើយបច្ចុប្បន្នគាត់កំពុងបន្តការសិក្សាផ្នែកអេស៊ីស៊ីអេ។

ស្រីនាង បានចាប់ផ្តើមការងាររបស់គាត់ក្នុងឆ្នាំ២០០៦ក្នុងតួនាទីជាសវនករហើយបន្តការងារនេះអស់រយៈពេលប្រាំមួយឆ្នាំកន្លះ។ គាត់មានបទពិសោធន៍ធ្វើសវនកម្មជាមួយស្ថាប័នជាច្រើនដូចជាៈ ក្រុមហ៊ុនសាជីវកម្ម ធនាគារ និងអង្គការក្រៅរដ្ឋាភិបាល។ គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅក្រុមហ៊ុនសវនកម្ម ប្រាយវ៉តធ័រហោស យូបភ័រស៍ ប្រទេសម៉ាឡេស៊ីរយៈពេល១៤ខែ។
ស្រីនាង បានចូលបម្រើការងារនៅធនាគារហ្វីលីព ក្នុងខែមេសា ឆ្នាំ២០១៥ក្នុងតួនាទីជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ។




**លោក ស្រ៊ុន វ៉ាន់ឌឿន**
**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

វ៉ានឌឿន បានបញ្ចប់ការសិក្សាផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ ន័រតុន។ គាត់មានបទពិសោធន៍ផ្នែកសវនកម្មរយៈពេលប្រាំពីរឆ្នាំជាមួយស្ថាប័នហិរញ្ញវត្ថុពីរគឺ ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ និងធនាគារកម្ពុជាសាធារណៈ។ កំឡុងពេលដប់ឆ្នាំជាមួយស្ថាប័នហិរញ្ញវត្ថុ គាត់ធ្លាប់បានបម្រើការងារក្នុងតួនាទីជាបេឡាករ គណនេយ្យករ សវនករ និងប្រធានក្រុមសវនករ។ វ៉ាន់ឌឿន បានចូលបម្រើការងារនៅធនាគារ ហ្វីលីពក្នុងខែធ្នូ ឆ្នាំ២០១៤ ក្នុងតួនាទីជាសវនករផ្ទៃក្នុងជាន់ខ្ពស់។




**អ្នកស្រី សុជាតិ កណិកា**
**នាយកដ្ឋានរដ្ឋបាលឥណទាន**

កណិកា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកទីផ្សារ ពីវិទ្យាស្ថានជាតិគ្រប់គ្រង និង បរិញ្ញាបត្រផ្នែកអក្សរសាស្រ្តខ្មែរពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គាត់បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០០៦ ពីសាកលវិទ្យាល័យបៀលប្រាយ។

គាត់បានចាប់ផ្តើមការងារនៅឆ្នាំ២០០១ជាមួយក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិជាច្រើន។ បន្ទាប់ពីឆ្លងកាត់ការបម្រើការងារប្រាំមួយឆ្នាំជាមួយក្រុមហ៊ុនធានារ៉ាប់រង និងទូរគមនាគមន៍គាត់បានសម្រេចធ្វើការផ្លាស់ប្តូរមកធ្វើការក្នុងវិស័យធនាគារ ដែលពេលនោះគាត់បានបម្រើការងារនៅធនាគារកូរ៉េ និង ម៉ាឡេស៊ី។

គាត់បានចូលបម្រើការងារជាមួយធនាគារហ្វីលីព ក្នុងខែមេសា ឆ្នាំ២០១៥ងតួនាទីជាប្រធាននាយកដ្ឋានរដ្ឋបាលឥណទាន។




**អ្នកស្រី តី សុម៉ាណា**
**នាយកដ្ឋានទីផ្សារ**

សុម៉ាណា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យមេគង្គ កម្ពុជា និងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យន័រតុន។

គាត់បានចាប់ផ្តើមការងារដំបូងជាបុគ្គលិកជំនួយការរដ្ឋបាលក្នុងឆ្នាំ២០០៤ នៅសាកលវិទ្យាល័យមេគង្គកម្ពុជា បន្ទាប់មកបានផ្លាស់ប្តូរការងារទៅជាបុគ្គលិកផ្នែកលក់នៅក្រុមហ៊ុនឯកជន។ ក្នុងឆ្នាំ២០០៨ គាត់បានចាប់ផ្តើមអាជីពជាបុគ្គលិកធនាគារជាមួយធនាគារ អេអិនហ្សិតរ៉ូយ៉ាល់។ ជាមួយបទពិសោធន៍រយៈពេលប្រាំបីឆ្នាំក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ គាត់បានបំពេញតួនាទីសំខាន់ៗមួយចំនួនដូចជា ផ្នែកលក់ ផ្នែកគាំទ្រ ផ្នែកអភិវឌ្ឍផលិតផល ជាប្រធានសាខា និងផ្នែកអភិវឌ្ឍអាជីវកម្ម។

ដោយសារការខិតខំក្នុងការងារ ក៏ដូចជាការអភិវឌ្ឍន៍ខ្លួនជាបន្តបន្ទាប់ ធ្វើអោយ សុម៉ាណា អាចទទួលបានឱកាសការងារជា ប្រធាននាយកដ្ឋានទីផ្សារជាមួយធនាគារ ហ្វីលីព ចាប់ពីខែមិថុនា ឆ្នាំ២០១៥ រហូតមក។

# គុណតម្លៃ



1. មនុស្សត្រូវបានបង្កើតឡើងដោយព្រះ ដូច្នេះមនុស្សមានសក្តានុពលខ្លាំងក្លា។
2. យើងលើកទឹកចិត្តបុគ្គលិករបស់យើងឲ្យអភិវឌ្ឍសមត្ថភាពរបស់គាត់មានដោយផ្តល់ឱកាសសិក្សាក្នុងវគ្គបណ្តុះបណ្តាលសេវា និងការទទួលខុសត្រូវ។
3. យើងឲ្យតម្លៃសច្ចភាពក្នុងការអនុវត្តរបស់យើង។ ភាពស្មោះត្រង់គឺជាការនិយាយការពិត សច្ចភាពគឺជាការធ្វើឲ្យក្លាយជាការពិត។
4. យើងជឿជាក់លើដំណើរការនៃការលើកទឹកចិត្ត ដែលរង្វាន់អាចមានតែក្រោយពេលការបំពេញការងារប៉ុណ្ណោះ។ ការងារដែលធ្វើបានល្អនាំមកនូវការពេញចិត្ត។
5. យើងចង់ធ្វើអាជីវកម្មជាជាងធ្វើពាណិជ្ជកម្ម ហើយដូច្នេះយើងនៅមានផ្លូវដ៏សែនឆ្ងាយទៀត។
6. យើងចាត់ទុកខ្លួនឯងជាអ្នកបម្រើរបស់អតិថិជន គ្រួសារ សហគមន៍របស់យើង និងមនុស្សដែលនៅជុំវិញខ្លួន។
7. យើងជាអ្នកការពាររបស់ក្រុមគ្រួសាររបស់យើង។
8. យើងនឹងលេងល្បែងដែលមានលទ្ធផលវិជ្ជមានតែប៉ុណ្ណោះ។

# ធនធានរបស់យើង

ធនាគារ ហ្វីលីព ភីអិលស៊ី  ចាត់ទុកបុគ្គលិករបស់ខ្លួនជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុត។ យើងបន្តពង្រឹងចំណេះដឹងនិងជំនាញរបស់បុគ្គលិករបស់យើងដោយផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងជំនាញទំនាក់ទំនង ដូច្នេះ ពួកគេអាចបម្រើអតិថិជនបានកាន់តែល្អ។ ទន្ទឹមគ្នានេះដែរ យើងក៏បានបង្កើតកម្មវិធីសម្រាប់សិក្ខាកាមដែលមិនទាន់បញ្ចប់ការសិក្សា ដើម្បីផ្តល់ឱកាសសម្រាប់សិស្សនិស្សិតដែលមានទេពកោសល្យមកសិក្សាអំពីប្រតិបត្តិការធនាគារ។ យើងចង់ចូលរួមក្នុងការអភិវឌ្ឍសង្គម និងចង់ឃើញមនុស្សជំនាន់ក្រោយរបស់ប្រទេសកម្ពុជាមានអនាគតភ្លឺស្វាង។ ការបណ្តុះបណ្តាលមានដូចជា៖ សិល្បៈនៃការលក់ ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំសម័យទំនើប របៀបក្លាយជាបុគ្គលិកឆ្នើម ជំនាញឥណទាន ហានិភ័យប្រតិបត្តិការ និងជំនាញផ្សេងៗទៀត។

# ទំនួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម



ក្នុងនាមជាអង្គភាពសាជីវកម្មទទួលខុសត្រូវមួយ ធនាគារ ហ្វីលីព ភីអិលស៊ី មានការប្តេជ្ញាចិត្តយ៉ាងខ្ពស់ចំពោះសង្គមនិងសហគមន៍ដែលយើងកំពុងរស់នៅ។ យើងជឿជាក់លើក្រុមសាជីវកម្មដែលដឹកនាំសកម្មភាព និងការសម្រេចចិត្តដែលយើងបានធ្វើជារៀងរាល់ថ្ងៃក្នុងអាជីវកម្មរបស់យើង។កាលពីឆ្នាំ២០១៥ ធនាគារ ហ្វីលីព ភីអិលស៊ី បានគាំទ្រកម្មវិធីសប្បុរសធម៌មួយចំនួនក្នុងតំបន់ និងក្នុងសហគមន៍ផងដែរ។សកម្មភាពទាំងនោះមានដូចជា៖

- សមាគមសហគ្រិនវ័យក្មេងកម្ពុជា៖ គោលបំណងគឺដើម្បីទទួលស្គាល់ និងលើកកម្ពស់សារគាររបស់សហគ្រិនវ័យក្មេង បង្កើតចំណាប់អារម្មណ៍និងបំផុសទឹកចិត្តរបស់សហគ្រិន និងដើម្បីស្វែងយល់ពីសហគ្រិនវ័យក្មេងដែលមានសមត្ថភាពក្នុងប្រទេសកម្ពុជាក្នុងកម្រិតថ្នាក់ជាតិ និងជួយដឹកនាំទៅការប្រកួតប្រជែងអន្តរជាតិ។
- ទេសភាពយន្តខ្មែរ៖ ធនាគារ ហ្វីលីព ភីអិលស៊ី ចូលរួមសហការធ្វើជាដៃគូឧបត្ថម្ភជាមួយរោងភាពយន្តផ្លាទីនៀមស៊ីណេផ្លិច ក្នុងការនាំយកភាពយន្តខ្មែរល្បីៗអំឡុងទស្សវត្ស ៦០, ៧០ និង ៩០ ដើម្បីរំឭកកេរ្តិ៍មរតកភាពយន្តខ្មែរ។ ប្រាក់ខែដែលបានមកពីការលក់សំបុត្រទាំងអស់ត្រូវបានបរិច្ចាគទៅមន្ទីរពេទ្យគន្ធបុប្ផា។
- ព្រឹត្តិការណ៍សប្បុរសធម៌ហ្សាំបាតុន៖ មហារីកសុដន់ជាជំងឺដែលកើតឡើងចំពោះស្ត្រីភាគច្រើន។ ហេតុដូច្នេះធនាគារ ហ្វីលីព ភីអិលស៊ី បានឧបត្ថម្ភដល់កម្មវិធី Advance Learning Academy ដែលសហការជាមួយអង្គការហេលស៍ ផូវើធី អ៊ែកហ្សិន ដើម្បីរៀបចំពិធីដើម្បីរៀបចំពិធីជប់លៀង ពណ៌ស៊ីជម្ពូក្នុងព្រឹត្តិការណ៍សប្បុរសធម៌ហ្សាំបាតុនដំបូងគេបង្អស់ក្នុងប្រទេសកម្ពុជាដើម្បីលើកកម្ពស់ការយល់ដឹង និងប្រមូលមូលនិធិសម្រាប់កម្មវិធីបម្រើសហគមន៍ និងការស្រាវជ្រាវជំងឺមហារីកសុដន់។ ចំណូលដែលបានមកពីព្រឹត្តិការណ៍នឹងប្រើសម្រាប់ឧបត្ថម្ភដល់មន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម។ មន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹមនៅតែជាមន្ទីរពេទ្យតែមួយគត់ក្នុងប្រទេសកម្ពុជាដែលផ្តល់ការពិនិត្យ រោគវិនិច្ឆ័យ ការអប់រំ ការបណ្តុះបណ្តាល និងព្យាបាលជំងឺមហារីកសុដន់ដោយឥតគិតថ្លៃដល់អ្នកជំងឺក្រីក្រ។






# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល



**លទ្ធផលអាជីវកម្ម និង ភាគលាភ**

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ មានដូចខាងក្រោម៖

| ដុល្លារអាមេរិច | ក្រុមហ៊ុនរួម | | ធនាគារ | |
|---|---|---|---|---|
| | ២០១៥<br>ដុល្លា | ២០១៤<br>ដុល្លា | ២០១៥<br>ដុល្លា | ២០១៤<br>ដុល្លា |
| ចំណេញ (ខាត) មុនពេលបង់ពន្ធ | (៣០០.១៤៣) | ២០៥.១៤៤ | (៣០០.១០៤) | ២០៩,០៩៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៥៣.១២០) | (៤៤.៣៤៧) | (៥៣.១២០) | (៤៤,៣៤៧) |
| **ចំណេញ(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ** | (៣៥៣.២៦៣) | ១៦០.៧៩៧ | (៣៥៣.២២៤) | ១៦៤,៧៤៧ |
| **សមមូល-ពាន់រៀល** | (១.៤៣០.៧១៣) | ៦៥៥.២៤៨ | (១.៤៣០.៥៥៥) | ៦៧១,៣៤៤ |
| ត្រូវបែងចែកដូចខាងក្រោម៖ | | | | |
| **មូលធនម្ចាស់ភាគហ៊ុនធនាគារ** | (៣៥៣.២៦៣) | ១៦០.៧៩៧ | (៣៥៣.២២៤) | ១៦៤,៧៤៧ |

**ដើមទុន**

ដើមទុនរបស់ធនាគារនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ មានចំនួន ៤១លានដុល្លាអាមេរិក ឬ ១៦៦.០៥ពាន់លានរៀល (ឆ្នាំ២០១៤៖៤០លានដុល្លាអាមេរិក ឬ ១៦៣ ពាន់លានរៀល)។

**ទុនបម្រុងនិង សំវិធានធន**

គណនីទុនបម្រុង និងសំវិធានធនសម្រាប់ការិយបរិច្ឆេទនេះពុំមានការផ្លាស់ប្តូរជាសារវន្តទេ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ឥណទាន និងបុរេប្រទានជាប់សង្ស័យ និងពិបាកទារ**

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីកំណត់ពីសកម្មភាពដែលត្រូវអនុវត្តក្នុងការលុបចោលឥណទាន និងបុរេប្រទានដែលទារមិនបាន និងការធ្វើសំវិធានធន សម្រាប់ការខាតបង់ចំពោះឥណទាននិងបុរេប្រទាន និងមានការជឿជាក់ថារាល់បំណុលនិងបុរេប្រទាន ដែលបានដឹងថាមិនអាចទារបានត្រូវបានលុបចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់សម្រាប់ឥណទាន និងបុរេប្រទានដែល ជាប់សង្ស័យ និងពិបាកទារ។មកទល់នឹងកាលបរិច្ឆេទ នៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានកត់សម្គាល់ឃើញពីហេតុការណ៍ណាមួយដែលនឹងបណ្តាលអោយចំនួនទឹកប្រាក់ដែលលុបចោលចំពោះឥណទាន និងបុរេប្រទានទារមិនបាន ឬចំនួនទឹកប្រាក់ សំវិធានធនចំពោះឥណទាន និងបុរេប្រទានជាប់សង្ស័យ និងពិបាកទារ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមិនគ្រប់គ្រាន់រហូតដល់កម្រិតសារវន្តណាមួយនោះទេ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមនិង ធនាគារត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាទ្រព្យសកម្មចរន្តដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ក្នុងតម្លៃស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានលើទីផ្សារ។ មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ឃើញពីហេតុការណ៍ណាមួយដែល នឹងធ្វើអោយប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ ថាមានភាពមិនត្រឹមត្រូវឬមិនសមស្របណាមួយនោះទេ។

## វិធីសាស្ត្រនៃការវាយតម្លៃ

មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាលឃើញពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃ ទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមានភាពមិនត្រឹមត្រូវ ឬ មិនសមស្របណាមួនណោះទេ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេង។

មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ

- ពុំមានការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនរួម និងធនាគារ ដែលកើតឡើងនៅដំណាច់ការិយបរិច្ឆេទ សម្រាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយនិង
- ពុំមានទ្រព្យអកម្មយថាភាពណាមួយកើតឡើងចំពោះក្រុមហ៊ុនរួម និងធនាគារចាប់តាំងពីដំណាច់ការិយបរិច្ឆេទ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ។

ពុំមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ ក្រុមហ៊ុនរួម និងធនាគារដែលត្រូវមានកាតព្វកិច្ចអនុវត្ត ឬអាចនឹងត្រូវមានកាតព្វកិច្ចអនុវត្តក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆទបញ្ចប់នេះ ដែលនឹងមានផលប៉ះពាល់ ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនរួម និងធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់នោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃតារាងតុល្យការ

ពុំមានព្រឹត្តិការណ៍ គួរអោយកត់សម្គាល់ណាមួយបានកើតឡើងក្រោយពីកាលបរិច្ឆេទតារាងតុល្យការ ដែលតម្រូវអោយមាន ការបង្ហាញ ឬការធ្វើនិយ័តកម្មចំពោះរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីព្រឹត្តិការណ៍ដូចមានបង្ហាញក្នុងកំណត់ សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សានៅក្នុងការិយបរិច្ឆេទ និងមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះមាននាមដូចខាងក្រោម៖

| | |
|---|---|
| លោក **LIM HUA MIN** | ប្រធាន |
| លោក **ONG TEONG HOON** | អភិបាល |
| លោក **TAN TECK KEONG MICHAEL** | អភិបាល |
| លោក **ចាន់ ម៉ាច** | អភិបាល |
| លោក **PAUL GWEE CHOON GUAN** | អភិបាលឯករាជ្យ |
| លោកស្រី **DIANA SEAH YEN GOON** | អភិបាលឯករាជ្យ |
| លោក **KOH YONG GUAN** | អភិបាលឯករាជ្យ |
| លោក **LEE SOON KIE** | អភិបាល ដែលលាលែងពីតំណែងនៅថ្ងៃ ១២ ខែតុលា ឆ្នាំ ២០១៥ |

## សវនករ

ក្រុមហ៊ុនសវនកម្មឯករាជ្យ **ERNST & YOUNG (CAMBODIA) LTD.** គឺជាសវនកររបស់ធនាគារ។

## ភាគហ៊ុនកាន់កាប់ដោយអភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ មានភាគហ៊ុនផ្ទាល់ នៅក្នុងធនាគារ នាចុងកាលបរិច្ឆេទនេះទេ។

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងនិងនាចុងការិយបរិច្ឆេទនេះ ពុំមានការព្រមព្រៀងណាមួយ ដែលមានធនាគារចូលរួមជាភាគីម្ខាងទៀត ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ អោយទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីសាមីធនាគារ

□ឬពីក្រុមហ៊ុនដ៏ទៃទៀតទេ។
ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាមួយរបស់ធនាគារ បានទទួល ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងធនាគារ និងក្រុមប្រឹក្សាភិបាល ឬរវាងធនាគារនិងក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមប្រឹក្សាភិបាលនោះ ឬជាមួយនឹងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុសំខាន់ៗជាមួយគ្នា ក្រៅពីប្រតិបត្តិការដូចមានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

### របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញនូវទិដ្ឋភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រងដែលត្រូវបានតម្រូវអោយ៖

១. អនុម័តនូវគោលនយោបាយគណនេយ្យ សមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផលនិងប្រកបដោយការប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍។

២. អនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា ព្រមទាំងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលតម្រូវដោយធនាគារជាតិ នៃកម្ពុជា ហើយប្រសិនបើការស្វែងរកទិដ្ឋភាពពិតប្រាកដតម្រូវអោយប្រើវិធានដទៃទៀតដែលខុសពីវិធានមុន វិធានថ្មីនេះត្រូវបានបង្ហាញនិងពន្យល់អោយបានច្បាស់លាស់ និងកំណត់បរិមាណនៃការប្រែប្រួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកនូវបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអោយមានប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុនរួមនឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត។

៥. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនរួម និងធនាគារប្រកបដោយប្រសិទ្ធភាព លើការសំរេចចិត្តដែលអាចប៉ះពាល់ជាសារវន្តដល់ប្រតិបត្តិការ និងដំណើរការអាជីវកម្មរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ ឲ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយនិងធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុនរួម និងធនាគារ ហើយម្យ៉ាងទៀតក៏ត្រូវចាត់ វិធានការសមស្របដើម្បីទប់ស្កាត់ និងស្វែងរកកំហុសចេតនា ហើយនិងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក្រុមហ៊ុនរួម និងធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ ជាក្រុមប្រឹក្សាភិបាល បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមានភ្ជាប់នេះថាបានបង្ហាញនូវ ទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិង ស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទ បញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ព្រមទាំងបទប្បញ្ញត្តិ និង គោលការណ៍ណែនាំ ពាក់ព័ន្ធរបស់ធនាគារជាតិ នៃ កម្ពុជា។

តំណាងក្រុមប្រឹក្សាភិបាល




**Ong Teong Hoon**
អភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៦

## ជូនចំពោះភាគទុនិកនៃធនាគារ ហ្វីលីព ភីអិលស៊ី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ហ្វីលីព ភីអិលស៊ី (“ធនាគារ”) និង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (រួមគ្នាហៅថា“ក្រុមហ៊ុនរួម”) និងរបាយការណ៍ហិរញ្ញវត្ថុ ដាច់ដោយឡែករបស់ ធនាគារ ដែលរួមមានតារាងតុល្យការរួម និងដាច់ដោយឡែកនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងរបាយការណ៍ លទ្ធផលរួម និងដាច់ដោយឡែក របាយការណ៍បម្រែបម្រួលមូលធនរួម និងដាច់ដោយឡែក ព្រមទាំងរបាយការណ៍ លំហូរសាច់ប្រាក់រួម និងដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងគោលនយោបាយគណនេយ្យ សំខាន់ៗ និងកំណត់សម្គាល់ផ្សេងៗទៀត (រួមគ្នាហៅថា “របាយការណ៍ហិរញ្ញវត្ថុ“)។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយផ្អែកលើមូលដ្ឋាននៃការងារសវនកម្ម។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។   ស្តង់ដារទាំងនេះ តម្រូវឲ្យយើងខ្ញុំអនុវត្តន៍តាមតម្រូវការនៃក្រមសីលធម៌ និងរៀបចំផែនការ និងបំពេញការងារ   សវនកម្ម ដើម្បីទទួលបាននូវការធានាសមហេតុផល ដើម្បីអះអាងថារបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជា   សារវន្តឡើយ។

ការងារសវនកម្មយើងខ្ញុំ រួមមានការអនុវត្តនីតិវិធីទាំងឡាយ ដើម្បីទទួលបាននូវភស្តុតាងសវនកម្ម ដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់សម្គាល់ទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ រាល់នីតិវិធីដែលបានជ្រើសរើសខាងលើ គឺពឹងផ្អែកទៅលើការវិនិច្ឆ័យរបស់សវនករ ដោយរាប់បញ្ចូលនូវការវាយតម្លៃទៅលើហានិភ័យលើភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។ ក្នុងការវាយតម្លៃលើហានិភ័យទាំងនោះ សវនករបានពិនិត្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំនិងការបង្ហាញពីទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម ដើម្បីរៀបចំនីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែការវាយតម្លៃទាំងនោះមិនមែនសម្រាប់គោលបំណងក្នុងការបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនរួមនោះទេ។ ការងារសវនកម្មរបស់យើងខ្ញុំ ក៏រួមបញ្ចូលផងដែរនូវការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋាន ក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## មតិយោបល់របស់សវនករ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកនេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមនិងធនាគារនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុរួម និងដាច់ដោយឡែក និងលំហូរសាច់ប្រាក់រួម និងដាច់ដោយឡែក សំរាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា។

Maria Cristina M. Calimbas
Partner

Maria Cristina M. Calimbas

Partner Ernst & Young (Cambodia) Ltd.

ក្រុមហ៊ុនគណនេយ្យករជំនាញ និងសវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២៣ខែមីនា ឆ្នាំ២០១៦

# តារាងតុល្យការរួម

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥



| | កំណត់សម្គាល់ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ | ៣ | ៤.១៥១.០៣៤ | ១៦.៨១១.៦៨៨ | ២.៨៤៩.៤៧៤ | ១១,៦១១,៦០៧ |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | ៤ | ១៧.៧២៤.៥០០ | ៧១.៧៨៤.២២៥ | ១៦.៥៥១.៣៩៦ | ៦៧,៤៤៦,៩៣៩ |
| សមតុល្យជាមួយធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៥ | ៧.៦៩៤.២៨៤ | ៣១.១៦១.៨៥០ | ១៩.៦៧៨.៥៧៤ | ៨០,១៩០,១៨៩ |
| វិនិយោគមូលបត្រ | ៦ | ២៥.០០០ | ១០១.២៥០ | ៥២៥.០០០ | ២,១៣៩,៣៧៥ |
| ឥណទាន និងបុរេប្រទាន | ៧ | ៦៨.៤៧៩.៥៣១ | ២៧៧.៣៤២.១០១ | ៣៧.៨១៥.៦០២ | ១៥៤,០៩៨,៥៧៨ |
| ទ្រព្យ និងបរិក្ខារ | ៩ | ១.៩០១.១៥៤ | ៧.៦៩៩.៦៧៥ | ៩៩៥.៩៤២ | ៤,០៥៨,៤៦៥ |
| កម្មវិធីកុំព្យូទ័រ | ១០ | ១៤០.០៩៧ | ៥៦៧.៣៩៣ | ១១១.៧៣២ | ៤៥៥,៣០៨ |
| ទ្រព្យសកម្មផ្សេងៗ | ១១ | ៥២៨.១៩០ | ២.១៣៩.១៦៩ | ៦០៧.៩៣៣ | ២,៤៧៧,៣២៦ |
| **ទ្រព្យសកម្មសរុប** | | ១០០.៦៤៣.៧៩០ | ៤០៧.៦០៧.៣៥១ | ៧៩.១៣៥.៦៥៣ | ៣២២,៤៧៧,៧៨៧ |
| **ទ្រព្យអកម្ម និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១២ | ១៥.១២២.២៨៩ | ៦១.២៤៥.២៧០ | ១៣.៣៤៨.២៤៤ | ៥៤,៣៩៤,០៩៤ |
| ប្រាក់បញ្ញើពីអតិថិជន | ១៣ | ៤១.៨៦៥.៦១៣ | ១៦៩.៥៥៥.៧៣៤ | ២៦.៨៩៦.៨៤៣ | ១០៩,៦០៤,៦៣៦ |
| ពន្ធត្រូវបង់ | ១៤ | ៦.១៥៣ | ២៤.៩២០ | ៦.៣៦២ | ២៥,៩២៥ |
| កម្ចី | ១៥ | ៣.០០០.០០០ | ១២.១៥០.០០០ | - | - |
| ទ្រព្យអកម្មផ្សេងៗ | ១៦ | ១.៦៩៦.៣៣៥ | ៦.៨៧០.១៥៧ | ៥៧៧.៥៤១ | ២,៣៥៣,៤៨០ |
| **ទ្រព្យអកម្មសរុប** | | ៦១.៦៩០.៣៩០ | ២៤៩.៨៤៦.០៨១ | ៤០.៨២៨.៩៩០ | ១៦៦,៣៧៨,១៣៥ |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | ១៧ | ៤១.០០០.០០០ | ១៦៦.០៥០.០០០ | ៤០.០០០.០០០ | ១៦៣,០០០,០០០ |
| ខាតបង្គរ | | (២.០៤៦.៦០០) | (៨.២៨៨.៧៣០) | (១.៦៩៣.៣៣៧) | (៦,៩០០,៣៤៨) |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | ៣៨.៩៥៣.៤០០ | ១៥៧.៧៦១.២៧០ | ៣៨.៣០៦.៦៦៣ | ១៥៦,០៩៩,៦៥២ |
| **ទ្រព្យអកម្ម និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | ១០០.៦៤៣.៧៩០ | ៤០៧.៦០៧.៣៥១ | ៧៩.១៣៥.៦៥៣ | ៣២២,៤៧៧,៧៨៧ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លទ្ធផលរួម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| ចំណូលប្រតិបត្តិការ | | | | | |
| ចំណូលការប្រាក់ | ១៨ | ៤.៨៦៨.៥៩៦ | ១៩.៧១៧.៨១៤ | ៣.៨៥៩.៦៦៨ | ១៥.៧២៨.១៤៧ |
| ចំណាយការប្រាក់ | ១៩ | (១.៩៤៦.៨២៩) | (៧.៨៨៤.៦៥៦) | (១.០២៦.៩៤៤) | (៤.១៨៤.៧៩៦) |
| **ចំណូលការប្រាក់សុទ្ធ** | | ២.៩២១.៧៦៧ | ១១.៨៣៣.១៥៨ | ២.៨៣២.៧២៤ | ១១.៥៤៣.៣៥១ |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារ | ២០ | ៦៧៦.៤៨៤ | ២.៧៣៩.៧៦០ | ៣១៦.១៨២ | ១.២៨៨.៤៤២ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ២២.៨៥៤ | ៩២.៥៥៩ | ៣.៦៧១ | ១៤.៩៥៩ |
| **ចំណូលប្រតិបត្តិការសរុប** | | ៣.៦២១.១០៥ | ១៤.៦៦៥.៤៧៧ | ៣.១៥២.៥៧៧ | ១២.៨៤៦.៧៥២ |
| ចំណាយបុគ្គលិក | ២២ | (១.៦៤៦.១២៦) | (៦.៦៦៦.៨១០) | (១.៤២៩.០៧៨) | (៥.៨២៣.៤៩៣) |
| ចំណាយពាក់ព័ន្ធការបង្កើត | ២៣ | (៨៦៤.៥៧៥) | (៣.៥០១.៥២៩) | (៦៣៩.៧៤៤) | (២.៦០៦.៩៥៧) |
| រលស់ | ២៤ | (៥១៣.៣៥៤) | (២.០៧៩.០៨៤) | (៣១២.០៧០) | ១.២៧១.៦៨៥ |
| **ចំណាយផ្សព្វផ្សាយ និង ទីផ្សារ** | ២៥ | (៥១៣.៣៥៤) | (២.០៧៩.០៨៤) | (៣១២.០៧០) | (១.២៧១.៦៨៥) |
| ចំណាយរដ្ឋបាលនិងចំណាយទូទៅ | ២៦ | (១៦៦.១៣៩) | (៦៧២.៨៦៣) | (១៤៦.៣០០) | (៥៩៦.១៧៣) |
| ការទាញបានមកវិញ (សំវិធានធន) | | (៧១៣.៧០៨) | (២.៨៩០.៥១៧) | (៦២៤.៥០១) | (២.៥៤៤.៨៤២) |
| លើការខាតលើឥណទាន និងបុរេប្រទាន | ៧ | (១៧.៣៤៦) | (៧០.២៥១) | ២០៤.២៦០ | ៨៣២.៣៦០ |
| **(ខាត) ចំណេញ មុនបង់ពន្ធ** | | (៣០០.១៤៣) | (១.២១៥.៥៧៧) | ២០៥.១៤៤ | ៨៣៥.៩៦២ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៤ | (៥៣.១២០) | (២១៥.១៣៦) | (៤៤.៣៤៧) | (១៨០.៧១៤) |
| **(ខាត) ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (៣៥៣.២៦៣) | (១.៤៣០.៧១៣) | ១៦០.៧៩៧ | ៦៥៥.២៤៨ |
| **បែងចែកទៅមូលធនម្ចាស់ភាគហ៊ុនធនាគារ** | | (៣៥៣.២៦៣) | (១.៤៣០.៧១៣) | ១៦០.៧៩៧ | ៦៥៥.២៤៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍បម្រែបម្រួលមូលធនរួម
សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥



| | ដើមទុន (កំណត់សម្គាល់ ១៧) ដុល្លារអាមេរិក | ខាតបង្គរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៥ | ៤០.០០០.០០០ | ៤០.០០០.០០០ | ៤០.០០០.០០០ |
| ដើមទុនបន្ថែម | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - |
| **សមតុល្យនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥** | ៤១.០០០.០០០ | ៤១.០០០.០០០ | ៤១.០០០.០០០ |
| **សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១)** | ១៦៦.០៥០.០០០ | ១៦៦.០៥០.០០០ | ១៦៦.០៥០.០០០ |
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៤ | ៤០.០០០.០០០ | ៤០.០០០.០០០ | ៤០.០០០.០០០ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | ៤០.០០០.០០០ | ៤០.០០០.០០០ | ៤០.០០០.០០០ |
| **សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១)** | ១៦៣.០០០.០០០ | ១៦៣.០០០.០០០ | ១៦៣.០០០.០០០ |

# របាយការណ៍លំហូរសាច់ប្រាក់រួម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់សុទ្ធ(ប្រើក្នុង) បានពីសកម្មភាពប្រតិបត្តិការ | ២៧ | (១២.០១២.១២៧) | (៤៨.៩៥៣.៤១២) | ៣.១៤៨.៩៧៤ | ១២.៨៣២.០៦៩ |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | | | | | |
| ចំណូលពី៖ | | | ២.០២៥.០០០ | - | - |
| ការដល់កាលកំណត់នៃវិនិយោគមូលបត្រ | ៦ | ៥០០.០០០ | ២.០២៥.០០០ | | |
| ការលក់ទ្រព្យ និងបរិក្ខារ | | ៤.៩៥២ | ២០.០៥៦ | ១៦.៩២១ | ៦៨.៩៤៣ |
| ចំណាយលើការទិញ៖ | | | | | |
| ទ្រព្យ និងបរិក្ខារ | ៩ | (១.៤៣៦.៤៦២)- | (៥.៨១៧.៦៧១)- | (៦៨៧.៩៣១) | (២.៨០៣.៣១៩) |
| វិនិយោគមូលបត្រ | ៦ | | | | |
| កម្មវិធីកុំព្យូទ័រ | ១០ | (៣០.៩៨៩) | (១២៥.៥០៥) | (៨១.៩៤៧) | (៣៣៣.៩៣៤) |
| សាច់ប្រាក់សុទ្ធប្រើក្នុង សកម្មភាពវិនិយោគ | | ៩៦២.៤៩៩ | ៣.៨៩៨.១២០ | ១.២៥២.៩៥៧ | ៥.១០៥.៨០០ |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | | | | | |
| ចំណូលបានមកពី៖ | | | | - | |
| ប្រាក់កម្ចី | ១៥ | ៣.០០០.០០០ | ១២.១៥០.០០០ | - | |
| ដើមទុនបន្ថែម | ១៧ | ១.០០០.០០០ | ៤.០៥០.០០០ | - | |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ៤.០០០.០០០ | ១៦.២០០.០០០ | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល(ថយ)កើនសុទ្ធក្នុងការិយបរិច្ឆេទ | | (៨.៩៧៤.៦២៦) | (៣៦.៦៥១.៥៣២) | ១.៨៩៦.០១៧ | ៧.៧២៦.២៦៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ | | ២៣.៥១៣.៨៤៤- | ៩៥.៨១៨.៩១៥ | ២១.៦១៧.៨២៧- | ៨៦.៣៦៣.២១៩ |
| លំអៀងពីអត្រាប្តូរប្រាក់ | | | ២៨៣.៥៥០ | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៣ | ១៤.៥៣៩.២១៨ | ៥៨.៨៨៣.៨៣៣ | ២៣.៥១៣.៨៤៤ | ៩៥.៨១៨.៩១៥ |
| នៅចុងការិយបរិច្ឆេទ | | | | | |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# តារាងតុល្យការដាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥



| | កំណត់សម្គាល់ | ២០១៥ ដុល្លារអាមេរិក | ២០១៥ សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ | ៣ | ៤.១៥១.០៣៤ | ១៦.៨១១.៦៨៨ | ២.៨៤៩.៤៧៤ | ១១.៦១១.៦០៧ |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | ៤ | ១៧.៧២៤.៥០០ | ៧១.៧៨៤.២២៥ | ១៦.៥៥១.៣៩៦ | ៦៧.៤៤៦.៩៣៩ |
| សមតុល្យជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៥ | ៧.៦៩៤.២៨៤ | ៣១.១៦១.៨៥០ | ១៩.៦៧៨.៥៧៤ | ៨០.១៩០.១៨៩ |
| វិនិយោគមូលបត្រ | ៦ | ២៥.០០០ | ១០១.២៥០ | ៥២៥.០០០ | ២.១៣៩.៣៧៥ |
| ឥណទាន និងបុរេប្រទាន | ៧ | ៦៨.៤៧៩.៥៣១ | ២៧៧.៣៤២.១០១ | ៣៧.៨១៥.៦០២ | ១៥៤.០៩៨.៥៧៨ |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៨ | ៥.០០០.០០០ | ២០.២៥០.០០០ | ៥.០០០.០០០ | ២០.៣៧៥.០០០ |
| ទ្រព្យ និងបរិក្ខារ | ៩ | ១.៩០១.១៥៤ | ៧.៦៩៩.៦៧៥ | ៩៩៥.៩៤២ | ៤.០៥៨.៤៦៥ |
| កម្មវិធីកុំព្យូទ័រ | ១០ | ១៤០.០៩៧ | ៥៦៧.៣៩៣ | ១១១.៧៣២ | ៤៥៥.៣០៨ |
| ទ្រព្យសកម្មផ្សេងៗ | ១១ | ៥២៨.១៩០ | ២.១៣៩.១៦៩ | ៦០៧.៩៣៣ | ២.៤៧៧.៣២៦ |
| **ទ្រព្យសកម្មសរុប** | | **១០៥.៦៤៣.៧៩០** | **៤២៧.៨៥៧.៣៥១** | **៨៤.១៣៥.៦៥៣** | **៣៤២.៨៥២.៧៨៧** |
| **ទ្រព្យអកម្ម និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១២ | ១៥.១២២.២៨៩ | ៦១.២៤៥.២៧០ | ១៣.៣៤៨.២៤៤ | ៥៤.៣៩៤.០៩៤ |
| ប្រាក់បញ្ញើពីអតិថិជន | ១៣ | ៤៦.៨៣៨.៣០០ | ១៨៩.៦៩៥.១១៥ | ៣១.៨៦៩.៥៦៩ | ១២៩.៨៦៨.៤៩៤ |
| ពន្ធត្រូវបង់ | ១៤ | ៦.១៥៣ | ២៤.៩២០ | ៦.៣៦២ | ២៥.៩២៥ |
| កម្ចី | ១៥ | ៣.០០០.០០០ | ១២.១៥០.០០០ | - | - |
| ទ្រព្យអកម្មផ្សេងៗ | ១៦ | ១.៦៩៦.៣៣៥ | ៦.៨៧០.១៥៧ | ៥៧៧.៥៤១ | ២.៣៥៣.៤៨០ |
| ទ្រព្យអកម្មសរុប | | **៦៦.៦៦៣.០៧៧** | **២៦៩.៩៨៥.៤៦២** | **៤៥.៨០១.៧១៦** | **១៨៦.៦៤១.៩៩៣** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | ១៧ | ៤១.០០០.០០០ | ១៦៦.០៥០.០០០ | ៤០.០០០.០០០ | ១៦៣.០០០.០០០ |
| ខាតបង្គរ | | (២.០១៩.២៨៧) | (៨.១៧៨.១១១) | (១.៦៦៦.០៦៣) | (៦.៧៨៩.២០៦) |
| មូលធនម្ចាស់ភាគហ៊ុនសរុប | | ៣៨.៩៨០.៧១៣ | ១៥៧.៨៧១.៨៨៩ | ៣៨.៣៣៣.៩៣៧ | ១៥៦.២១០.៧៩៤ |
| **ទ្រព្យអកម្ម និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | **១០៥.៦៤៣.៧៩០** | **៤២៧.៨៥៧.៣៥១** | **៨៤.១៣៥.៦៥៣** | **៣៤២.៨៥២.៧៨៧** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លទ្ធផលដាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ ដុល្លារអាមេរិក | ២០១៥ សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
|---|---|---|---|---|---|
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | ១៨ | ៤.៨៦៨.៥៩៦ | ១៩.៧១៧.៨១៤ | ៣.៨៥៩.៦៦៨ | ១៥.៧២៨.១៤៧ |
| ចំណាយការប្រាក់ | ១៩ | (១.៩៤៦.៨២៩) | (៧.៨៨៤.៦៥៦) | (១.០២៦.៩៤៤) | (៤.១៨៤.៧៩៦) |
| **ចំណូលការប្រាក់សុទ្ធ** | | ២.៩២១.៧៦៧ | ១១.៨៣៣.១៥៨ | ២.៨៣២.៧២៤ | ១១.៥៤៣.៣៥១ |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារ | ២០ | ៦៧៨.៨០៥ | ២.៧៤៩.១៦០ | ៣១៦.១៩២ | ១.២៨៨.៤៨២ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ២០.៥៧២ | ៨៣.៣១៧ | ៣.៦៧១ | ១៤.៩៥៩ |
| **ចំណូលពីប្រតិបត្តិការសរុប** | | ៣.៦២១.១៤៤ | ១៤.៦៦៥.៦៣៥ | ៣.១៥២.៥៨៧ | ១២.៨៤៦.៧៩២ |
| ចំណាយបុគ្គលិក | ២២ | (១.៦៤៦.១២៦) | (៦.៦៦៦.៨១០) | (១.៤២៩.០៧៨) | (៥.៨២៣.៤៩៣) |
| ចំណាយពាក់ព័ន្ធការបង្កើត | ២៣ | (៨៦៤.៥៧៥) | (៣.៥០១.៥២៩) | (៦៣៩.៧៤៤) | (២.៦០៦.៩៥៧) |
| រំលស់ | ២៤ | (៥១៣.៣៥៤) | (២.០៧៩.០៨៤) | (៣១២.០៧០) | (១.២៧១.៦៨៥) |
| ចំណាយផ្សព្វផ្សាយ និង ទីផ្សារ | ២៥ | (១៦៦.១៣៩) | (៦៧២.៨៦៣) | (១៤៦.៣០០) | (៥៩៦.១៧៣) |
| ចំណាយរដ្ឋបាលនិងចំណាយទូទៅ | ២៦ | (៧១៣.៧០៨) | (២.៨៩០.៥១៧) | (៦២០.៥៦១) | (២.៥២៨.៧៨៦) |
| ការទាញបានមកវិញ (សំវិធានធន) លើការខាតលើឥណទាន និងបុរេប្រទាន | ៧ | (១៧.៣៤៦) | (៧០.២៥១) | ២០៤.២៦០ | ៨៣២.៣៦០ |
| **(ខាត) ចំណេញមុនបង់ពន្ធ** | | **(៣០០.១០៤)** | **(១.២១៥.៤១៩)** | **២០៩.០៩៤** | **៨៥២.០៥៨** |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៤ | (៥៣.១២០) | (២១៥.១៣៦) | (៤៤.៣៤៧) | (១៨០.៧១៤) |
| **(ខាត) ចំណេញសុទ្ធសម្រាប់ការិយាបរិច្ឆេទ** | | **(៣៥៣.២២៤)** | **(១.៤៣០.៥៥៥)** | **១៦៤.៧៤៧** | **៦៧១.៣៤៤** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | ដើមទុន (កំណត់សម្គាល់ ១៦) ដុល្លារអាមេរិក | ខាតបង្គរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៤០.០០០.០០០ | ១.៦៦៦.០៦៣ | ៣៨.៣៣៣.៩៣៧ |
| ដើមទុនបន្ថែម | ១.០០០.០០០ | | ១.០០០.០០០ |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | ៤១.០០០.០០០ | (២.០១៩.២៨៧) | ៣៨.៩៨០.៧១៣ |
| **ពាន់រៀល** (កណត់សម្គាល់ ២.១) | ១៦៦.០៥០.០០០ | (៨.១៧៨.១១១) | ១៥៧.៨៧១.៨៨៩ |
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ៤០.០០០.០០០ | (១.៩៣០.៨១០) | ៣៨.១៦៩.១៩០ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | ៤០.០០០.០០០ | (១.៦៦៦,០៦៣) | ៣៨.៣៣៣.៩៣៧ |
| **ពាន់រៀល** (កំណត់សម្គាល់ ២.១) | ១៦៣.០០០.០០០ | (៦.៧៨៩.២០៦) | ១៥៦.២១០.៧៩៤ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ៣៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរសាច់ប្រាក់ជាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ ដុល្លារអាមេរិក | ២០១៥ សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
|---|---|---|---|---|---|
| **សាច់ប្រាក់សុទ្ធបានពី (ប្រើក្នុង) សកម្មភាពប្រតិបត្តិការ** | ២៧ | (១២.០១២.១២៧) | (៤៨.៩៥៣.៤១២) | ៣.១៤៨.៩៧៤ | ១២.៨៣២.០៦៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| **ចំណូលពី៖** | | | | | |
| ការដល់កាលកំណត់នៃវិនិយោគមូលបត្រ | ៦ | ៥០០.០០០ | ២.០២៥.០០០ | - | - |
| ការលក់ទ្រព្យ និងបរិក្ខារ | | ៤.៩៥២ | ២០.០៥៦ | ១៦.៩២១ | ៦៨.៩៥៣ |
| **ចំណាយលើការទិញ៖** | | | | | |
| ទ្រព្យ និងបរិក្ខារ | ៩ | (១.៤៣៦.៤៦២) | (៥.៨១៧.៦៧១) | (៦៨៧.៩៣១) | (២.៨០៣.៣១៩) |
| កម្មវិធីកុំព្យូទ័រ | ១០ | (៣០,៩៨៩) | (១២៥,៥០៥) | (៨១,៩៤៧) | (៣៣៣,៩៣៤) |
| វិនិយោគមូលបត្រ | ៦ | - | - | (៥០០.០០០) | (២.០៣៧.៥០០) |
| **សាច់ប្រាក់សុទ្ធប្រើក្នុង សកម្មភាពវិនិយោគ** | | **(៩៦២.៤៩៩)** | **(៣.៨៩៨.១២០)** | **(១.២៥២.៩៥៧)** | **(៥.១០៥.៨០០)** |
| **លំហូរសាច់ប្រាក់ពីសកម្មហិរញ្ញប្បទាន** | | | | | |
| ចំណូលបានមកពី កម្ចី | ១៥ | ៣.០០០.០០០ | ១២.១៥០.០០០ | - | - |
| ដើមទុនបន្ថែម | ១៧ | ១.០០០.០០០ | ៤.០៥០.០០០ | - | - |
| **សាច់ប្រាក់សុទ្ធបានពីក្នុងសកម្មភាពហិរញ្ញប្បទាន** | | ៤.០០០.០០០ | ១៦.២០០.០០០ | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល (ថយ) កើនសុទ្ធក្នុងការិយបរិច្ឆេទ** | | (៨.៩៧៤.៦២៦) | (៣៦.៦៥១.៥៣២) | ១.៨៩៦.០១៧ | ៧.៧២៦.២៦៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ | | ២៣.៥១៣.៨៤៤ | ៩៥.៨១៨.៩១៥ | ២១.៦១៧.៨២៧ | ៨៦.៣៦៣.២១៩ |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | (២៨៣.៥៥០) | - | ១.៧២៩.៤២៧ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | ៣ | **១៤.៥៣៩.២១៨** | **៥៨.៨៨៣.៨៣៣** | **២៣.៥១៣.៨៤៤** | **៩៥.៨១៨.៩១៥** |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥



## ១. ព័ត៌មានអំពីធនាគារ

ធនាគារ ហ្វីលីព ភីអិលស៊ី (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (រួមគ្នាហៅថា“ក្រុមហ៊ុនរួម“) ត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ការបង្កើត និងប្រតិបត្តិការ

ធនាគារជាធនាគារពាណិជ្ជដែលបានចុះបញ្ជី និង បង្កើតឡើងនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩។ ធនាគារពីមុនមកជាកម្មសិទ្ធិរបស់ Hwang DBS (Malaysia) Berhad ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ដែលបានចុះបញ្ជីនៅប្រទេសម៉ាឡេស៊ី។ ធនាគារ ត្រូវបានចុះបញ្ជីអាជីវកម្ម ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានផ្តល់ អាជ្ញាប័ណ្ណដោយ បទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ធនាគារត្រូវបានផ្ទេរកម្មសិទ្ធិទៅអោយ Phillip MFIs Pte Ltd ជាសមាជិកនៃ PhillipCapital Groupដែលចុះបញ្ជីនៅប្រទេសសិង្ហបុរី។ លិខិតស្នើរការផ្ទេរកម្មសិទ្ធិ ភាគហ៊ុនត្រូវបានអនុម័តជាបន្ទាប់ដោយធនាគារជាតិ នៃ កម្ពុជា នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤។ បន្ទាប់ពីទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា ធនាគារបញ្ជូនលិខិតស្នើរជាបន្តទៅកាន់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ដើម្បីកែប្រែលក្ខន្តិកៈក្រុមហ៊ុន។ ការអនុម័តត្រូវទទួលបានពីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៤។

ធនាគារប្រតិបត្តិការអាជីវកម្ម ដែលស្ថិតនៅក្រោមការត្រួតពិនិត្យនៃសកម្មភាពធនាគារ និង សេវាកម្ម ហិរញ្ញវត្ថុពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុលោមតាមអាជ្ញាប័ណ្ណធនាគារលេខ ៥៩១៥/0៩E ដែលចេញដោយធនាគារជាតិ នៃ កម្ពុជាសំរាប់អំឡុងពេលមិនជាក់លាក់។
ទីស្នាក់ការចុះបញ្ជីរបស់ធនាគារ មានទីតាំងនៅអគារលេខ ២៧ DEF មហាវិថី ព្រះមុនីវង្ស សង្កាត់ ស្រះចកខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរដែលគួរអោយកត់សម្គាល់ ទៅលើសកម្មភាពប្រតិបត្តិការសំខាន់ៗ ដែលបានរៀបរាប់ខាងលើឡើយក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុនេះ។ ក្រុមហ៊ុន HwangDBS Securities (Cambodia) Plc (“ក្រុមហ៊ុនបុត្រសម្ព័ន្ធ”) ត្រូវបានបង្កើតឡើង នៅថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០១០។ ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនអសកម្មភាព និង មិនមានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មខ្លួនឡើយ។ នាការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនបុត្រសម្ព័ន្ធស្ថិតក្រោមការជំរះបញ្ជី។
របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៦។

### ដើមទុន

ដើមទុនរបស់ធនាគារ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានចំនួន ៤១.000.000 ដុល្លារអាមេរិក (ឆ្នាំ២០១៤៖ ៤0.000.000 ដុល្លារអាមេរិក)។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងការិយបរិច្ឆេទ និងមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មាននាមដូចខាងក្រោម៖

| | |
|---|---|
| លោក Lim Hua Min | ប្រធាន |
| លោក Ong Teong Hoon | អភិបាល |
| លោក Tan Teck Keong Michael | អភិបាល |
| លោក ចាន់ ម៉ាច | អភិបាល |
| លោក Paul Gwee Choon Guan | អភិបាល ឯករាជ្យ |
| លោកស្រី Diana Seah Yen Goon | អភិបាល ឯករាជ្យ |
| លោក Koh Yong Guan | អភិបាល ឯករាជ្យ |
| លោក Lee Soon Kie | អភិបាល ដែលលាលែងពីតំណែង នៅថ្ងៃ ១២ ខែតុលា ឆ្នាំ២០១៥ |

### បុគ្គលិក

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ធនាគារមានបុគ្គលិកសរុបចំនួន ១៤៦ នាក់(ឆ្នាំ២០១៤៖១០២ នាក់)។

## ២. គោលនយោបាយគណនេយ្យ



គោលនយោបាយគណនេយ្យសំខាន់ៗដែលប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកមានកំណត់ដូចខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងជាប់លាប់ នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញ លើកលែងតែមានការលើកឡើងផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក (ហៅថា "របាយការណ៍ហិរញ្ញវត្ថុ") ត្រូវបានរៀបចំតាមសម្មតិកម្មថ្លៃដើមប្រវត្តិសាស្ត្រ។ ក្រុមហ៊ុនរួមបានកត់ត្រា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាទឹកប្រាក់ដុល្លារអាមេរិក ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០៧-១៦៤ ចុះ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការប្រើប្រាស់ភាសា ឯកតារូបិយប័ណ្ណ និងអត្រាប្តូរប្រាក់សម្រាប់កិច្ចបញ្ជីកាគណនេយ្យ និងរបាយការណ៍។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំចេញដោយធនាគារជាតិ នៃ កម្ពុជា។ការប្រែសម្រួលទឹកប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមប្រកាសលេខ ធ៧-០៧-១៦៤ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ការប្រើប្រាស់ អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៥០ រៀល (ឆ្នាំ២០១៤៖១ ដុល្លារអាមេរិកស្មើនឹង ៤.០៧៥រៀល)។
ដូច្នេះ តួលេខប្រែសម្រួលជាប្រាក់រៀលដែលបានបង្ហាញនេះ និងមិនគួរត្រូវយកមកបកស្រាយថា ជាតួលេខដែលអាចត្រូវបាន ឬនឹងត្រូវបាន ឬនាពេលអនាគត នឹងត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នេះ ឬអត្រាផ្សេងៗទៀតបានឡើយ។

**ឆ្នាំសារពើពន្ធ**
ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនរួម គឺចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

### ២.២ ការវិនិច្ឆ័យ និង ការប៉ាន់ស្មានគណនេយ្យសំខាន់។

ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរួម ថ្នាក់ដឹកនាំបានធ្វើការវិនិច្ឆ័យនិងការប៉ាន់ស្មានរបស់ខ្លួន ក្នុងការកំណត់ចំនួនទឹកប្រាក់ដែលត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម៖

#### ២.២.១ ការខាតបង់សំវិធានធនលើឥណទាន និងបុរេប្រទានចំពោះអតិថិជន

នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គុណភាពនៃឥណទាន និងបុរេប្រទានត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដើម្បីកំណត់ចំណាត់ថ្នាក់ និងកម្រិតនៃសំវិធានធននៃការខាតបង់ លើឥណទាន និងបុរេប្រទាន ដូចមានបង្ហាញទាំងស្រុងនៅក្នុងកំណត់សម្គាល់លេខ ២.៣.៥។

#### ២.២.២ ភតិសន្យាប្រតិបត្តិ

ធនាគារបានចុះកិច្ចសន្យាជួលអចលនទ្រព្យ ក្នុងនាមជាអ្នកជួលសំរាប់អគារការិយាល័យរបស់ខ្លួន។ ធនាគារបានកំណត់ថា ម្ចាស់អគារជាអ្នករ៉ាប់រងលើរាល់ហានិភ័យធំៗ និងជាម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យនេះ ដោយផ្អែកទៅតាមសូចនាករណ៍នៃភតិសន្យាប្រតិបត្តិ។ នៅក្នុងការកំណត់ថាមាន ឬ មិនមានសូចនាករណ៍នៃការអនុវត្តន៍ភតិសន្យាប្រតិបត្តិ ធនាគារពិចារណាលើកត្តា ដូចជា៖ ការរក្សាទុកប្លង់កម្មសិទ្ធិរបស់អចលនទ្រព្យដែលបានជួល និងរយៈពេលនៃកិច្ចសន្យាជួល ទាក់ទងជាមួយនឹងការប៉ាន់ស្មានរយៈពេលប្រើប្រាស់សេដ្ឋកិច្ចរបស់អចលនទ្រព្យ ដែលបានជួលជាមួយនិងថ្លៃរត់ការ និងថ្លៃផ្សេងៗ។

### ២.៣. សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់។

#### ២.៣.១ ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

គោលនយោបាយគណនេយ្យ និងវិធីសាស្ត្រនៃការគណនាត្រូវបានអនុវត្តជានិច្ចកាល ដោយ ធនាគារ ដូចដែលបានអនុវត្តក្នុងការិយបរិច្ឆេទកន្លងមក។

#### ២.៣.២ ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គដែលធនាគារមានលទ្ធភាពក្នុងគ្រប់គ្រងហិរញ្ញវត្ថុ នឹងគោលនិយោបាយប្រតិបត្តិការដើម្បីទទួលផងប្រយោជន៍ពីសកម្មភាពរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ។ វត្តមាន និងឥទ្ធិពលនៃសិទ្ធិបោះឆ្នោតដែលមានសក្តានុពលដែលអាចប្រើប្រាស់ ឬប្តូរបានបច្ចុប្បន្នត្រូវបានពិចារណានៅពេលវាយតម្លៃ ថាធនាគារមានអំណាចបែបនឹងទៅលើអង្គភាពផ្សេងទៀត ឬយ៉ាងណា
។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារកាលវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានបង្ហាញតាមថ្លៃដើមដកការខាតបង់នៃការថយចុះតម្លៃ។ បើមានការលក់ការវិនិយោគនេះទឹកប្រាក់ខុសគ្នារវាងចំណូលសុទ្ធពីការលក់ និងតម្លៃចុះបញ្ជីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល។

### ២.៣.៣ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

របាយការណ៍ហិរញ្ញវត្ថុរួម រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ នាការិយបរិច្ឆេទនៃតារាងតុល្យការ។ របាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរៀបចំឡើងដូចការិយបរិច្ឆេទរបាយការណ៍របស់ធនាគារផងដែរ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរួមបញ្ចូលចាប់ពីថ្ងៃទិញ ដែលជាថ្ងៃដែលធនាគារទទួលបាន ការគ្រប់គ្រង និងបន្តរួមបញ្ចូលរហូតដល់ថ្ងៃបញ្ចប់ការគ្រប់គ្រង។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម សមតុល្យផ្ទៃក្នុង ប្រតិបត្តិការ និងចំណេញ ឬខាតដែលមិនច្បាស់លាស់ត្រូវបានលុបចោលទាំងអស់។ គោលនយោបាយគណនេយ្យមានលក្ខណៈតែមួយត្រូវបានអនុវត្តនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរួមចំពោះប្រតិបត្តិការ និងព្រឹត្តិការណ៍ទាំងឡាយណាស្ថិតក្នុងកាលៈទេសៈស្រដៀងគ្នា។

ការទិញក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកត់ត្រាដោយប្រើប្រាស់វិធីសាស្ត្រទិញ។ វិធីសាស្ត្រគណនេយ្យ ទិញទាក់ទងទៅនឹងការបែងចែកថ្លៃដើមនៃការទិញទៅនឹងតម្លៃទីផ្សារនៃទ្រព្យសកម្ម ដែលបានទិញ និងបំណុល និងបំណុលយថាហេតុដែលបានសន្មតនៅថ្ងៃទិញ។ ថ្លៃដើមទិញត្រូវបានវាស់វែង ជាតម្លៃសរុបនៃតម្លៃទីផ្សារនាថ្ងៃដោះដូរនៃទ្រព្យសកម្ម ដែលបានទទួលបំណុលដែលបានកើតឡើង ឬដែលបានសន្មត និងឧបករណ៍មូលធនដែលបានចេញផ្សាយ បូកថែមថ្លៃដើមផ្ទាល់ផ្សេងៗដែលពាក់ព័ន្ធនឹងការទិញ។

### ២.៣.៤ ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាន ត្រូវបានបង្ហាញក្នុងតារាងតុល្យការជាទឹកប្រាក់ដើម ដោយដកចេញនូវឥណទានដែលត្រូវបានលុបចោល និងសំវិធានធនដែលមានលើឥណទាន និង បុរេប្រទានទាំងនោះ។
ឥណទាន និងបុរេប្រទាន ត្រូវបានលុបចោល នៅពេលដែលធនាគារមើលឃើញយ៉ាងច្បាស់លាស់ ថាឥណទាន និងបុរេប្រទានមិនអាចប្រមូលមកវិញបាន។ ការប្រមូលបានមកវិញនៃឥណទាន និងបុរេប្រទាន ដែលត្រូវបានលុបចោល ឬបានធ្វើសំវិធានធននៅក្នុងការិយបរិច្ឆេទមុនៗនឹងបន្ថយទឹកប្រាក់នៃសំវិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទាននៅក្នុងរបាយការណ៍លទ្ធផល។ឥណទាននិងបុរេប្រទានដែលត្រូវបានចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារសង្ស័យ ឬ បាត់បង់ គឺត្រូវចាត់ទុកជាឥណទានមិនដំណើរការ។

### ២.៣.៥ វិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទាន

សំវិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទានត្រូវបានធ្វើឡើងដោយអាស្រ័យទៅលើ ហានិភ័យជាក់លាក់នានា ដែលទាក់ទងទៅនឹងឥណទាននិងបុរេប្រទានទាំងនោះ ដែលត្រូវបានពិនិត្យមើលឡើងវិញ និងកំណត់យ៉ាងជាក់លាក់ថាជាឥណទានឃ្លាំមើលក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់។ លើសពីនេះ សំវិធានធនទូទៅក៏ត្រូវបានធ្វើឡើងផងដែរសម្រាប់ឥណទានដែលបានចាត់ថ្នាក់ជាឥណទានធម្មតា។

សំវិធានធនត្រូវបានគណនាដោយផ្អែកទៅតាមភាគរយនៃសមតុល្យឥណទាន និងបុរេប្រទាននៅសល់សរុប។
ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដូចដែលបានតម្រូវដោយ ធនាគារជាតិនៃកម្ពុជា តាមប្រកាសលេខ ធ៧-០៩-០៧៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩។
ប្រកាសនេះ តម្រូវអោយធនាគារពាណិជ្ជទាំងអស់ចាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជា ៥ថ្នាក់។ កម្រិតស្របច្បាប់ចាំបាច់នៃការធ្វើសំវិធានធនទូទៅនិងជាក់លាក់ត្រូវបានធ្វើឡើងដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដូចមានបង្ហាញជូនខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់ | អត្រាសំវិធានធន |
|---|---|---|
| **សំវិធានធនទូទៅ** | | |
| ឥណទានធម្មតា | គ្មាន រហូតដល់តិចជាង៣០ថ្ងៃ | ១% |
| **សំវិធានធនជាក់លាក់** | | |
| ឥណទានឃ្លាំមើល | ពី ៣០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ៩០ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ពី ៩០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ១៨០ ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ពី១៨០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង៣៦០ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ៣៦០ថ្ងៃ ឬ ច្រើនជាង | ១០០% |

### ២.៣.៥ វិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទាន ( តពីទំព័រមុន )



ឥណទានមិនអាចប្រមូលបាន ឬចំណែកឥណទានដែលចាត់ចំណាត់ថ្នាក់ជាឥណទានអាក្រក់ ត្រូវបានលុបចោល បន្ទាប់ពីការពិចារណាលើតម្លៃទីផ្សារជាក់ស្តែងរបស់អចលនទ្រព្យដាក់បញ្ចាំ និងបន្ទាប់ពីការវិនិច្ឆ័យរបស់ថ្នាក់ដឹកនាំធនាគារ ថាមិនមានសង្ឃឹមក្នុងការប្រមូលមកវិញបាន។

### ២.៣.៦កិច្ចសន្យាឥណទានផ្សេង។

ក្នុងដំណើរការអាជីវកម្មធម្មតាក្រុមហ៊ុនរួមបានធ្វើកិច្ចសន្យាឥណទានផ្សេងៗ រួមមានកិច្ចសន្យាផ្តល់ ឥណទាន លិខិតឥណទាននិងលិខិតធានា។ គោលនយោបាយគណនេយ្យ និងវិធីសាស្រ្ត សំវិធានធន គឺប្រហាក់ប្រហែលគ្នាទៅនឹងការផ្តល់ឥណទាន ដូចមានក្នុងកំណត់សម្គាល់ខាងលើ។ សំវិធានធនជាក់លាក់ ត្រូវបានធ្វើឡើងចំពោះកិច្ចសន្យាឥណទានផ្សេងៗ នៅពេលការបាត់បង់ ត្រូវបានគិតថាអាចនឹងកើតមានឡើង។

### ២.៣.៧ វិនិយោគមានសំរាប់លក់

វិនិយោគមានសំរាប់លក់បាន គឺការវិនិយោគហិរញ្ញវត្ថុទាំងឡាយណា ដែលអាចត្រូវបានកំណត់ទុក ជាមុន ឬមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការចាត់ថ្នាក់ជា ការកំណត់ទុកជាមុននូវតម្លៃទីផ្សារ តាមរយៈប្រាក់ចំណេញ និងខាត កាន់កាប់ដល់ថ្ងៃកាលកំណត់ ឬឥណទាន និងប្រាក់បុរេប្រទាន។

### ២.៣.៨មូលបត្របំណុលមិនមានថ្លៃទីផ្សារ

មូលបត្របំណុលមិនមានថ្លៃទីផ្សារ គឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិនមែននិស្សន្ទ ដែលមានការចំណាយថេរ ឬ ដែលអាចកំណត់មុន និងមានកាលកំណត់ថេរ សម្រាប់គណៈគ្រប់គ្រងធនាគារមានគោលបំណងវិជ្ជមាន និង លទ្ធភាពកាន់កាប់ដល់កាលកំណត់។

### ២.៣.៩ការកំណត់ថ្លៃទីផ្សារ

តម្លៃទីផ្សារសំរាប់ឧបករណ៍ហិរញ្ញវត្ថុដែលចរាចរក្នុងទីផ្សារ នៅកាលបរិច្ឆេទតារាងតុល្យការ គឺត្រូវបានផ្អែកលើតម្លៃទីផ្សារ ឬ តារាងតម្លៃរបស់ប្រតិបត្តិការនៃឧបករណ៍ហិរញ្ញវត្ថុនោះ (តម្លៃទិញសំរាប់ ការវិនិយោគរយៈពេលវែង និង តម្លៃដាក់លក់សំរាប់ការវិនិយោគរយៈពេលខ្លី ) ដោយមិនមានការ កាត់កងជាមួយថ្លៃប្រតិបត្តិការ។ សំរាប់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលមិនត្រូវបានចរាចរក្នុងទីផ្សារ តម្លៃទីផ្សារត្រូវបាន កំណត់ដោយប្រើបច្ចេកទេសវាយតម្លៃសមស្រប។

### ២.៣.១០ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងគ្នាហើយចំនួនទឹកប្រាក់សុទ្ធត្រូវបាន បង្ហាញក្នុងតារាងតុល្យការតែក្នុងករណីដែលមានសិទ្ធិស្របច្បាប់ អោយធ្វើការកាត់កងទឹកប្រាក់ ដែលបានទទួលស្គាល់ហើយមានបំណងទូទាត់តាមមូលដ្ឋានសុទ្ធ ឬលក់ទ្រព្យសកម្ម និងទូទាត់ ទ្រព្យអកម្ម នៅពេលទន្ទឹមគ្នានោះ។ ជាទូទៅ នេះមិនមែនជាករណីរបស់កិច្ចព្រមព្រៀងកាត់កងឡើយ ហើយទ្រព្យសកម្ម និង ទ្រព្យអកម្មពាក់ព័ន្ធត្រូវបានបង្ហាញជាទឹកប្រាក់ដុលក្នុងតារាងតុល្យការ។

### ២.៣.១១ ការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុរវាងទ្រព្យអកម្ម និង មូលធន

ឧបករណ៍ហិរញ្ញវត្ថុត្រូវបានចាត់ទុកជាបំណុល ប្រសិនជាវាផ្តល់កាតព្វកិច្ចតាមកិច្ចសន្យាដើម្បីៈ

- ផ្ទេរសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅកាន់ក្រុមហ៊ុនដទៃ
- ដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុជាមួយក្រុមហ៊ុនដទៃក្រោមល័ក្ខខ័ណ្ឌ ដែលមានភាពអវិជ្ជមានខ្លាំងលើក្រុមហ៊ុនរួម
- បំពេញបាននូវកាតព្វកិច្ច ជាជាងដោយការដោះដូរនៃសាច់ប្រាក់ថេរ ឬទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀត សំរាប់ចំនួនថេរនៃភាគហ៊ុនមូលធនផ្ទាល់។
- ប្រសិនបើក្រុមហ៊ុនរួម មិនមានសិទ្ធិដែលគ្មានល័ក្ខខ័ណ្ឌដើម្បីជៀសវាងការផ្ទេរសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅកាន់ក្រុមហ៊ុនដទៃ ដើម្បីសងកាតព្វកិច្ចតាមកិច្ចសន្យា ដូចនេះកាតព្វកិច្ចត្រូវនឹងនិយមន័យនៃទ្រព្យអកម្មហិរញ្ញវត្ថុ។

### ២.៣.១២ការទទួលស្គាល់ចំណូល ឬ ចំណាយ

ចំណូលត្រូវបានទទួលស្គាល់ត្រឹមកម្រិតដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ច នឹងហូរចូលមកក្នុងក្រុមហ៊ុនរួម ហើយចំណូលនេះអាចវាស់វែងគួរអោយជឿជាក់បាន។ ចំណូលការប្រាក់ពីឥណទាន និងប្រាក់បុរេប្រទានអោយអតិថិជន ហើយនិងសមតុល្យជាមួយធនាគារជាតិ នៃ កម្ពុជា និងជាមួយគ្រឹះស្ថានធនាគារផ្សេងៗ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានគណនេយ្យ បង្គរប្រចាំថ្ងៃ លើកលែងតែការប្រាក់បង្គររបស់ឥណទានដែលត្រូវបានចាត់ថ្នាក់ក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់។ ការប្រាក់បង្គររបស់ឥណទានទាំងនោះត្រូវបានកត់ត្រាខាងឥណទាន នៃ គណនីការប្រាក់ព្យួរទុក។

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន និងគណនីសម្រាប់ទូទាត់របស់ធនាគារផ្សេងៗ និងលើប្រាក់កម្ចីត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ។ ក្រុមហ៊ុនរួមទទួលកំរៃឈ្នួល និង កំរៃជើងសារពីការផ្តល់សេវាកម្មផ្សេងៗទៅអតិថិជន។ កំរៃឈ្នួល និង កំរៃជើងសារត្រូវបានទទួលស្គាល់តាមមូលដ្ឋានសាច់ប្រាក់។ កំរៃឈ្នួល និង កំរៃជើងសារបានពីចំណូលសេវាផ្ទេរប្រាក់ចេញនិងចូល កំរៃដំណើរការ

ឥណទាន កំរៃធ្វើការ លិខិតធានា លិខិតឥណទាន និង កំរៃ សេវាប័ណ្ណ ATM ឬ ប័ណ្ណឥណទាន ។
ចំណាយលើកំរៃឈ្នួល និងកំរៃជើងសារត្រូវបានទទួលស្គាល់នៅពេលចំណាយនោះបានកើតឡើង។

### ២.៣.១៣ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សំរាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់សុទ្ធ និងសមតុល្យសាច់ប្រាក់លើកាលវិនិយោគរយៈពេលខ្លីផ្សេងៗ ដែលមាន អាយុកាលកំណត់ តិចជាង៩០ថ្ងៃ ដែលអាចប្តូរជាសាច់ប្រាក់បានឆាប់រហ័ស និងកាលដល់អាយុកាលនៃគណនីរបស់ធនាគរ ពីធនាគារផ្សេងៗ។

### ២.៣.១៤ ទ្រព្យ និងបរិក្ខារ និង កម្មវិធីកុំព្យូទ័រ

ទ្រព្យ និងបរិក្ខារ និង រួមបញ្ចូលកម្មវិធីកុំព្យូទ័រត្រូវបានកត់ត្រានូវតម្លៃដើម ដោយដកចេញនូវរំលស់បង្គរ និងសំវិធានធនលើការថយចុះតម្លៃ (ប្រសិនបើមាន)។ ការផ្លាស់ប្តូរអាយុកាលប្រើប្រាស់រំពឹងទុកត្រូវបានធ្វើឡើងដោយការផ្លាស់ប្តូររយៈពេល ឬ វិធីសាស្ត្ររំលស់អោយបានសមស្រប ហើយចាត់ទុកថាជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ។

ទ្រព្យ និងបរិក្ខារត្រូវបានឈប់ទទួលស្គាល់ នៅពេលលក់ចេញ ឬ នៅពេលប្រមើលមិនឃើញមានអត្ថប្រយោជន៍អនាគតបានពីការប្រើប្រាស់វានោះ។ ការចំណេញ ឬ ខាតលើការឈប់ទទួលស្គាល់ទ្រព្យសកម្ម (ដែលត្រូវបានគណនាជាចំនួនខុសគ្នា រវាងទឹកប្រាក់ដែលទទួលបានពីការលក់សុទ្ធ និងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មនោះ) ត្រូវបានទទួលស្គាល់ក្នុង “ចំណូលអាជីវកម្មផ្សេងៗទៀត” នៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំ ដែលទ្រព្យសកម្មនោះត្រូវបានឈប់ទទួលស្គាល់។

#### រំលស់

រំលស់នៃទ្រព្យ និងបរិក្ខារ និង កម្មវិធីកុំព្យូទ័រ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មទាំងអស់នេះ ដែលកំណត់ដូចខាងក្រោម ៖

| | |
|---|---|
| ការកែលំអអាគារ | ៥ ឆ្នាំ |
| បរិក្ខារការិយាល័យ | ៥ ឆ្នាំ |
| សង្ហារឹម និងបរិក្ខារ | ៥ ទៅ ១០ ឆ្នាំ |
| កុំព្យូទ័រ | ៣ ទៅ ៥ ឆ្នាំ |
| យានយន្ត | ៥ ឆ្នាំ |
| កម្មវិធីកុំព្យូទ័រ | ៥ ឆ្នាំ |

សំណង់កំពុងសាងសង់មិនត្រូវបានធ្វើរំលស់ទេ។

## ២.៣.១៥ ពន្ធលើប្រាក់ចំណេញ

### ពន្ធលើប្រាក់ចំណេញក្នុងគ្រា

ពន្ធលើប្រាក់ចំណេញក្នុងគ្រាជាទ្រព្យសកម្ម និងទ្រព្យអកម្ម សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និង មុនៗ ត្រូវបានវាស់វែងជាទឹកប្រាក់ដែលត្រូវបានរំពឹងទុកថា ត្រូវបានប្រមូលមកវិញ ឬត្រូវបានទូទាត់ទៅអាជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់ពន្ធ ដែលប្រើដើម្បីគណនាទឹកប្រាក់ទាំងនេះ គឺជាអត្រា និងច្បាប់ពន្ធដែលមានសុពលភាពនៅកាលបរិច្ឆេទនៃតារាងតុល្យការនេះ។

### ពន្ធលើប្រាក់ចំណេញពន្យារ

ពន្ធលើប្រាក់ចំណេញពន្យារ ត្រូវបានគណនា ដោយប្រើវិធីសាស្ត្របំណុលតុល្យការលើចំនួន ខុសគ្នាបណ្តោះអាសន្ន នាកាលបរិច្ឆេទនៃតារាងតុល្យការរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និង ទ្រព្យអកម្ម ហើយនិងតម្លៃពិតគណនេយ្យរបស់ទ្រព្យទាំងនោះក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធលើប្រាក់ចំណេញពន្យារជាទ្រព្យអកម្ម ត្រូវបានទទួលស្គាល់សម្រាប់ចំនួនខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាំងអស់ លើកលែងតែនៅពេលពន្ធពន្យារជាទ្រព្យអកម្មកើតឡើងពីការទទួលស្គាល់ នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬទ្រព្យអកម្ម នៅក្នុងប្រតិបត្តិការមួយដែលនៅពេលនោះ វាមិនជះឥទ្ធិពលដល់ប្រាក់ចំណេញតាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ប្រព័ន្ធ។
ពន្ធលើប្រាក់ចំណេញពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ដែលអាចកាត់បន្ថយបានរហូតដល់ទំហំមួយ ដែលទំនងថាប្រាក់ចំណេញជាប់ពន្ធ នឹង អាចមានដើម្បីកាត់កងជាមួយភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចប្រើប្រាស់បាន លើកលែងតែ នៅពេលពន្ធពន្យារជាទ្រព្យសកម្មកើតឡើងពីការទទួលស្គាល់នាគ្រាដំបូង នៃទ្រព្យសកម្ម ឬបំណុល នៃប្រតិបត្តិការមួយនៅខណៈពេលប្រតិបត្តិការកើតឡើងនោះ មិនមានឥទ្ធិពលដល់ប្រាក់ចំណេញ តាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬខាតជាប់ពន្ធ។

តម្លៃពិតគណនេយ្យនៃពន្ធលើប្រាក់ចំណេញពន្យារជាទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញ នាកាលបរិច្ឆេទនៃតារាងតុល្យការនីមួយៗ ហើយនិងត្រូវបានកាត់បន្ថយមកត្រឹមទំហំមួយ ដែលមិនទំនងថាមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នឹងអាចផ្តល់ឲ្យទ្រព្យសកម្មទាំងអស់ ឬមួយផ្នែកអាចប្រមូលមកវិញនាពេលអនាគត។

ពន្ធលើប្រាក់ចំណូលពន្យារ ជាទ្រព្យសកម្ម ដែលមិនត្រូវបានទទួលស្គាល់នោះ គឺត្រូវបានវាយតម្លៃឡើងវិញនាកាលបរិច្ឆេទ នៃតារាងតុល្យការនីមួយៗ ហើយត្រូវបានទទួលស្គាល់ត្រឹមតែទំហំមួយដែលវាទំនងថា ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងធ្វើឲ្យពន្ធពន្យារជាទ្រព្យសកម្មនោះ អាចត្រូវបានយកប្រមូលមកវិញបាន។

## ២.៣.១៦ ប្រតិបត្តិការ និងការប្រែសម្រួលរូបិយប័ណ្ណបរទេស

ក្រុមហ៊ុនរួម រក្សាប្រព័ន្ធគណនេយ្យ និងកត់ត្រាគ្រប់ប្រតិបត្តិការទាំងអស់ ជារូបិយប័ណ្ណជាក់ស្តែង។ ទ្រព្យសកម្ម និង ទ្រព្យអកម្ម ដែលជារូបិយប័ណ្ណបរទេសនាចុងការិយបរិច្ឆេទត្រូវបានប្រែសម្រួលឡើងវិញជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលកំណត់នៅកាលបរិច្ឆេទនៃរបាយការណ៍។ សំរាប់អត្រាប្តូរប្រាក់បច្ចុប្បន្ននៃប្រាក់ដុល្លារអាមេរិក និងរូបិយប័ណ្ណបរទេសដែលពាក់ព័ន្ធធៀប ទៅនឹងប្រាក់រៀល នៅថ្ងៃទី៣១ ខែធ្នូ យោងទៅកំណត់សំគាល់ ៣៣ ។
ចំណូល និងចំណាយដែលកើតឡើងជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិកនាចុងខែដោយប្រើអត្រាប្តូរប្រាក់មធ្យមសមស្រប ជាជាងអត្រាប្តូរប្រាក់ដែលកំណត់នាកាលបរិច្ឆេទនៃប្រតិបត្តិការ។

## ២.៣.១៧ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា លុះត្រាណាក្រុមហ៊ុនរួមមានកាតព្វកិច្ចនាពេលបច្ចុប្បន្នដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល និងដែលវាប្រហែលជានឹងអាចត្រូវមានលំហូរចេញនៃធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ចដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយទឹកប្រាក់នៃកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ប្រមាណដោយគួរអោយជឿជាក់បាន។

### ២.៣.១៨ ទ្រព្យសកម្មដែលស្ថិតក្រោមកិច្ចសន្យាធានា

ទ្រព្យសកម្មដែលផ្ញើរក្សាទុក ឬក្នុងសមាសភាពជាទ្រព្យដាក់ធានា គឺមិនត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ពីព្រោះទ្រព្យទាំងនេះមិនមែនជាទ្រព្យសកម្មរបស់ក្រុមហ៊ុនរួមឡើយ។

### ២.៣.១៩ប្រាក់បញ្ញើកាតព្វកិច្ច

ប្រាក់បញ្ញើកាតព្វកិច្ច ត្រូវរក្សានៅធនាគារជាតិ នៃកម្ពុជា ដោយអនុលោមតាមច្បាប់នៃធនាគារ និង ស្ថាប័នហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និង ត្រូវបានកំណត់ដោយភាគរយអប្បបរមានៃមូលធននិង ប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិ នៃកម្ពុជា។

### ២.៣.២០ ភតិសន្យា

ការបញ្ជាក់ថាតើកិច្ចសន្យាមួយជា ឬរួមបញ្ចូលជា ភតិសន្យាបាន គឺឈរលើមូលដ្ឋាននៃភាពពិតជាក់ស្តែងរបស់កិច្ចសន្យានាកាលបរិច្ឆេទចាប់ផ្តើមដំបូង ដែលថាតើការបំពេញលក្ខខណ្ឌនៃកិច្ចសន្យា នោះ គឺអាស្រ័យទៅលើការប្រើប្រាស់ទ្រព្យសកម្មមួយជាក់លាក់ ឬទ្រព្យសកម្មច្រើន ឬ កិច្ចសន្យានោះ ផ្ទេរសិទ្ធិដើម្បីប្រើប្រាស់ទ្រព្យសកម្មទាំងនោះ។

**ធនាគារដែលជាអ្នកជួល**

ភតិសន្យាដែលអ្នកជួលអោយរក្សាទុករាល់ហានិភ័យ និង អត្ថប្រយោជន៍ម្ចាស់កម្មសិទ្ធិទ្រព្យសកម្ម ត្រូវបានចាត់ថ្នាក់ក្នុងភតិសន្យាប្រតិបត្តិការ។ ការចំណាយភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងរបាយការណ៍ប្រាក់ចំណេញ ខាតតាមវិធីសាស្ត្ររំលស់ថេរដោយយោងទៅតាមរយៈពេលនៃភតិសន្យា។

### ២.៣.២១ ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ភាគីទាំងឡាយ ដែលចាត់ទុកថាជាសម្ព័ន្ធញាតិ ប្រសិនបើក្រុមហ៊ុនរួមមានលទ្ធភាពដោយផ្ទាល់ឬដោយប្រយោលដើម្បីគ្រប់គ្រងភាគីផ្សេងៗឬក៏មានឥទ្ធិពលខ្លាំងទៅលើភាគីទាំងនោះក្នុងការធ្វើសេចក្តីសំរេចលើប្រតិបត្តិការនិងហិរញ្ញវត្ថុ ឬផ្ទុយមកវិញ ឬនៅពេលដែលក្រុមហ៊ុនរួម និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬក៏មានឥទ្ធិពលខ្លាំង។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬ ជានីតិបុគ្គល និងរួមបញ្ចូលទាំង សាច់ញាតិជិតស្និទ្ធក្នុងសមាជិកគ្រួសារនៃរូបវន្តបុគ្គល ដែលចាត់ទុកថាជាសម្ព័ន្ធញាតិ។

សម្ព័ន្ធញាតិត្រូវបានកំណត់ក្នុងមាត្រា ៤៩ និង ៥០ នៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុរួមមានដូចខាងក្រោម៖

(ក) បុគ្គលទាំងឡាយណា ដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុន ឬសិទ្ធិបោះឆ្នោត។
(ខ) ក្រុមហ៊ុនណា ដែលក្រុមហ៊ុនរួមកាន់កាប់នៅក្នុងដើមទុនដោយផ្ទាល់ ឬដោយប្រយោលនូវ ភាគកម្មយ៉ាងតិចស្មើនឹងដប់ភាគរយ (១០%) ឬតំណាងយ៉ាងតិចដប់ភាគរយ (១០%) នៃសិទ្ធិ បោះឆ្នោត។
(គ) បុគ្គលណាដែលចូលរួមក្នុងការអភិបាល ការដឹកនាំ ការកាន់កាប់ ឬការត្រួតពិនិត្យផ្ទៃក្នុង។
(ឃ) សវនករឯករាជ្យ។

### ២.៣.២២ភាគលាភលើមូលធន

ភាគលាភមូលធនត្រូវបានទទួលស្គាល់ជាទ្រព្យអកម្ម និង កាត់កងពីមូលធនម្ចាស់ភាគហ៊ុននៅពេលដែលក្រុមប្រឹក្សាភិបាលអនុម័ត។ ភាគលាភប្រកាសក្នុងការិយបរិច្ឆេទ តែអនុម័តក្រោយបរិច្ឆេទរបាយការណ៍តុល្យការ ត្រូវបានរាយការណ៍ជាព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរបាយការណ៍។

### ២.៣.២៣ការកាត់ខ្ទង់ចំនួនទឹកប្រាក់

ចំនួនទឹកប្រាក់ដុល្លារអាមេរិកក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកាត់ខ្ទង់ដើម្បីអោយជិតបំផុតទៅនឹងចំនួនទឹកប្រាក់ជាដុល្លារអាមេរិក និងចំនួនទឹកប្រាក់រៀលជាខ្ទង់ពាន់រៀល លុះត្រាតែមានការបញ្ជាក់ផ្សេងក្រៅពីនេះ។

## ៣. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សំរាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល របស់ក្រុមហ៊ុនរួម និងធនាគាររួមមាន៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| សាច់ប្រាក់ក្នុងដៃ | ៤.១៥១.០៣៤ | ១៦.៨១១.៦៨៨ | ២.៨៤៩.៤៧៤ | ១១.៦១១.៦០៧ |
| សមតុល្យនៅធនាគារជាតិ | | | | |
| (កំណត់សម្គាល់ ៤) គណនីចរន្ត | ៥.៤៨៣.៩០០ | ២២.២០៩.៧៩៥ | ៦.៧៧៥.៧៩៦ | ២៧.៦១១.៣៦៩ |
| ប្រាក់បញ្ញើមានកាលកំណត់ * | ២.២១០.០០០ | ៨.៩៥០.៥០០ | ២.២១០.០០០ | ៩.០០៥.៧៥០ |
| សមតុល្យជាមួយធនាគារនិង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ (កំណត់សម្គាល់៥) | | | | |
| គណនីចរន្ត | ២.១៩៤.២៧៩ | ៨.៨៨៦.៨៣០ | ១.៦៧៨.៥៧៤ | ៦.៨៤០.១៨៩ |
| គណនីសន្សំ | ៥ | ២០ | | |
| ប្រាក់បញ្ញើមានកាលកំណត់ * | ៥០០.០០០ | ២.០២៥.០០០ | ១០.០០០.០០០ | ៤០.៧៥០.០០០ |
| | ១៤.៥៣៩.២១៨ | ៥៨.៨៨៣.៨៣៣ | ២៣.៥១៣.៨៤៤ | ៩៥.៨១៨.៩១៥ |

* ប្រាក់បញ្ញើមានកាលកំណត់មានរយៈពេល៣ខែ ឬ តិចជាង

## ៤. សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា

សមតុល្យសាច់ប្រាក់របស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| គណនីចរន្ត | ១.៨១៨.៦០៤ | ៧.៣៦៥.៣៤៦ | ៤.៣៤៦.៩០២ | ១៧.៧១៣.៦២៦ |
| គណនីសំរាប់កាត់កង | ៣.៦៦៥.២៩៦ | ១៤.៨៤៤.៤៩៩ | ២.៤២៨.៨៩៤ | ៩.៨៩៧.៧៤៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ២.២១០.០០០ | ៨.៩៥០.៥០០ | ២.២១០.០០០ | ៩.០០៥.៧៥០ |
| ប្រាក់បម្រុងកាតព្វកិច្ច | ៥.៩៣០.៦០០ | ២៤.០១៨.៩៣០ | ៣.៥៦៥.៦០០ | ១៤.៥២៩.៨២០ |
| ប្រាក់តម្កល់ធានាលើដើមទុន | ៤.១០០.០០០ | ១៦.៦០៥.០០០ | ៤.០០០.០០០ | ១៦.៣០០.០០០ |
| | **១៧.៧២៤.៥០០** | **៧១.៧៨៤.២២៥** | **១៦.៥៥១.៣៩៦** | **៦៧.៤៤៦.៩៣៩** |

### ប្រាក់បញ្ញើមានកាលកំណត់

បញ្ញើមានកាលកំណត់សំដៅលើប័ណ្ណបញ្ញើអាចចរចារបាន ដែលមានកាលកំណត់បីខែ។

### ប្រាក់បម្រុងកាតព្វកិច្ច

អនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា លេខ ធ៧-០៩-០៧៥ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ធនាគារត្រូវបានតម្រូវអោយរក្សាសាច់ប្រាក់បម្រុងជាក់លាក់នៅធនាគារជាតិ នៃកម្ពុជា ក្នុងទំរង់ជាប្រាក់បញ្ញើកាតព្វកិច្ចដោយគណនាតាមអត្រា ៨,០% នៃប្រាក់បញ្ញើរបស់អតិថិជនជាប្រាក់រៀល និង ១២,៥% នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណបរទេស។

### ប្រាក់តម្កល់ធានាលើដើមទុន

អនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា លេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ធនាគារត្រូវបានតម្រូវអោយតម្កល់ប្រាក់បញ្ញើដើមទុនកាតព្វកិច្ចចំនួន ១០% ភាគរយ នៃដើមទុនចុះបញ្ជី នៅធនាគារជាតិ នៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃបានឡើយ ប៉ុន្តែធនាគារអាចដកយកវិញបាននៅពេលដែលធនាគារស្ម័គ្រចិត្តឈប់ធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### អត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំ លើសមតុល្យនៅធនាគារជាតិ នៃកម្ពុជាមានដូចខាងក្រោម៖

| | ២០១៥ | ២០១៤ |
|---|---|---|
| គណនីចរន្ត និងគណនីសំរាប់កាត់កង | 0% | 0% |
| ប្រាក់បញ្ញើមានកាលកំណត់ | 0,២៣% | 0,១៧% |
| ប្រាក់បម្រុងកាតព្វកិច្ច | 0,១០% | 0,១០% |
| ប្រាក់តម្កល់ធានាលើដើមទុន | 0,១១% | 0,០៨% |

## ៥. សមតុល្យជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ



ក្រុមហ៊ុនរួម និង ធនាគារមានសមតុល្យជាមួយធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| គណនចរន្ត និងសន្សំជាមួយ៖ | | | | |
| ធនាគារក្រៅប្រទេស | - | - | ១.៥៩១.២៩៣ | ៦.៤៨៤.៥១៩ |
| ធនាគារក្នុងប្រទេស | ២.១៩៤.២៨៤ | ៨.៨៨៦.៨៥០ | ៨៧.២៨១ | ៣៥៥.៦៧០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៥.៥០០.០០០ | ២២.២៧៥.០០០ | ១៨.០០០.០០០ | ៧៣.៣៥០.០០០ |
| | ៧.៦៩៤.២៨៤ | ៣១.១៦១.៨៥០ | ១៩.៦៧៨.៥៧៤ | ៨០.១៩០.១៨៩ |

គណនីចរន្តដែលរក្សាទុកនៅធនាគារក្នុង និង ក្រៅប្រទេសពុំទទួលបានការប្រាក់ទេ។
ប្រាក់បញ្ញើមានកាលកំណត់ទទួលបានការប្រាក់ ៥,២០% ក្នុងមួយឆ្នាំ (ឆ្នាំ២០១៤៖ ៣,១០% ក្នុងមួយឆ្នាំ)។

## ៦. វិនិយោគមូលបត្រ

ក្រុមហ៊ុនរួម និង ធនាគារមានវិនិយោគមូលបត្រដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| វិនិយោគលើមូលធនផ្សេងៗ | ២៥.០០០ | ១០១.២៥០ | ២៥.០០០ | ១០១.៨៧៥ |
| មូលបត្របំណុលមិនមានថ្លៃទីផ្សារ | - | - | ៥០០.០០០ | ២.០៣៧.៥០០ |
| | ២៥.០០០ | ១០១.២៥០ | ៥២៥.០០០ | ២.១៣៩.៣៧៥ |

វិនិយោគលើមូលធនផ្សេងៗគឺជាការវិនិយោគនៅ Credit Bureau of Cambodia។ ថ្លៃទីផ្សារមិនអាចកំណត់ដោយជាក់លាក់បាន ដោយសារតែភាពមិនអាចព្យាករណ៍បានលើលំហូរសាច់ប្រាក់នាពេលអនាគត និងកង្វះខាតវិធីសាស្រ្តសមស្របនៃការទាញយកថ្លៃទីផ្សារ ដែលអាចជឿជាក់បាន។ ការវិនិយោគនេះគឺកត់ត្រាតាមថ្លៃដើម។

មូលបត្របំណុលមិនមានថ្លៃទីផ្សារសំដៅលើ មូលបត្របំណុលសាជីវកម្មពីធនាគារឯកទេស Cam Capital ។ វិនិយោគនេះមានកាលកំណត់ ៦ខែ និងមានអត្រាការប្រាក់ ៦,៥០% ក្នុងមួយឆ្នាំ ហើយត្រូវបានប្រមូលត្រលប់មកវិញនាកាលបរិច្ឆេទកំណត់។

## ៧. ឥណទាននិងបុរេប្រទាន

ឥណទាន និងបុរេប្រទានរបស់ក្រុមហ៊ុនរួម និង ធនាគារមានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| ឥណទានមានកាលកំណត់ | ៥៩.៨២៣.៥៨២ | ២៤២.២៨៥.៥០៧ | ៣៥.៧២៤.៦៣៤ | ១៤៥.៥៧៧.៨៨៤ |
| ឥណទានវិបារូបន៍ | ១០.៤៥០.៣០៤ | ៤២.៣២៣.៧៣២ | ៣.៩២៨.០៣៨ | ១៦.០៦៦.៧៥៥ |
| ឥណទាន និង បុរេប្រទានដុល | ៧០.២៧៣.៨៨៦ | ២៨៤.៦០៩.២៣៩ | ៣៩.៦៥២.៦៧២ | ១៦១.៥៨៤.៦៣៩ |
| សំវិធានធនសម្រាប់ឥណទាន និងបុរេប្រទានបាត់បង់ | ១.៧៩៤.៣៥៥ | ៧.២៦៧.១៣៨ | ១.៨៣៧.០៧០ | ៧.៤៨៦.០៦១ |
| ឥណទាន និង បុរេប្រទានសុទ្ធ | **៦៨.៤៧៩.៥៣១** | **២៧៧.៣៤២.១០១** | **៣៧.៨១៥.៦០២** | **១៥៤.០៩៨.៥៧៨** |

ឥណទាន និង បុរេប្រទាន ត្រូវបានធ្វើការវិភាគបន្ថែម ដូចខាងក្រោម៖

ក)- បំរែបំរួលនៃសំវិធានធនសំរាប់ឥណទាន និង បុរេប្រទានបាត់បង់ ៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| សំវិធានធនជាក់លាក់៖ | | | | |
| នាដើមការិយបរិច្ឆេទ | ១.៤៦០.៨០៩ | ៥.៩៥៩.៧៦៧ | ១.៧៣៦.៨៨៩ | ៦.៩៣៨.៨៧២ |
| ការកត់ត្រាត្រលប់ក្នុងឆ្នាំ | (២៩៥.៣៨៦) | (១.១៩៦.៣១៣) | (២២៥.១០៩) | (៩១៧.៣១៩) |
| ការលុបចោល | (៦០.០៦១) | (២៤៣.២៤៧) | (៥០.៩៧១) | (២០៧.៧០៧) |
| លំអៀងនៃអត្រាប្តូរប្រាក់ | - | (៤៣.៤៩១) | - | ១៣៨.៩៥១ |
| នាចុងការិយបរិច្ឆេទ | ១.១០៥.៣៦២ | ៤.៤៧៦.៧១៦ | ១.៤៦០.៨០៩ | ៥.៩៥២.៧៩៧ |
| សំវិធានធនទូទៅ៖ | | | | |
| នាដើមការិយបរិច្ឆេទ | ៣៧៦.២៦១ | ១.៥៣៣.២៦៤ | ៣៥៥.៤១២ | ១.៤១៩.៨៧១ |
| បន្ថែមនៅក្នុងឆ្នាំ | ៣១២.៧៣២ | ១.២៦៦.៥៦៥ | ២០.៨៤៩ | ៨៤.៩៥៩ |
| លំអៀងនៃអត្រាប្តូរប្រាក់ | - | (៩.៤០៧) | - | ២៨.៤៣៤ |
| នាចុងការិយបរិច្ឆេទ | ៦៨៨.៩៩៣ | ២.៧៩០.៤២២ | ៣៧៦.២៦១ | ១.៥៣៣.២៦៤ |
| សំវិធានធនសរុបនាចុងការិយបរិច្ឆេទ | ១.៧៩៤.៣៥៥ | ៧.២៦៧.១៣៨ | ១.៨៣៧.០៧០ | ៧.៤៨៦.០៦១ |

## ៧. ឥណទាន និង បុរេប្រទាន (តពីទំព័រមុន)

ខ) ការកំណត់កម្រិតសំពាធឥណទានដុល និងសំវិធានធនដែលពាក់ព័ន្ធ សម្រាប់ឥណទាន និងបុរេប្រទានដែលបាត់បង់មានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| **ឥណទានធម្មតា៖** | | | | |
| មានវត្ថុធានា | ៦៣.៤៩៦.១៨៩ | ២៥៧.១៥៩.៥៦៥ | ៣៤.៥៣៨.៣៧៩ | ១៤០.៧៤៣.៨៩៥ |
| មិនមានវត្ថុធានា | ៥.៤០៣.០៨៦ | ២១.៨៨២.៤៩៨ | ៣.០៨៧.៦៧៣ | ១២.៥៨២.២៦៨ |
| **ឥណទានឃ្លាំមើល៖** | | | | |
| មានវត្ថុធានា | ២៦៨.២៩៨ | ១.០៨៦.៦០៧ | ៣៤៦.៣៤៦ | ១.៤១១.៣៦០ |
| មិនមានវត្ថុធានា | ២.៨៤៧ | ១១.៥៣០ | ៣៤.៦៤៦ | ១៤១.១៨២ |
| **ឥណទានក្រោមស្តង់ដារ៖** | | | | |
| មានវត្ថុធានា | ៤.៩២៧ | ១៩.៩៥៤ | ១៦៥.៨៧៣ | ៦៧៥.៩៣២ |
| មិនមានវត្ថុធានា | - | - | ៣២.១២១ | ១៣០.៨៩៣ |
| **ឥណទានសង្ស័យ៖** | | | | |
| មានវត្ថុធានា | - | - | ៦៦.០២៤ | ២៦៩.០៤៨ |
| មិនមានវត្ថុធានា | ៤.៥៩៣ | ១៨.៦០២ | ៩.៦៨៣ | ៣៩.៤៥៨ |
| **ឥណទានបាត់បង់៖** | | | | |
| មានវត្ថុធានា | ៨៩៨.៣៨០ | ៣.៦៣៨.៤៣៩ | ១.០៨៩.៨៥៤ | ៤.៤៤១.១៥៦ |
| មិនមានវត្ថុធានា | **១៩៥.៥៦៦** | **៧៩២.០៤៤** | **២៨២.០៧៣** | **១.១៤៩.៤៤៧** |
| សរុបឥណទានដុល | ៧០.២៧៣.៨៨៦ | ២៨៤.៦០៩.២៣៩ | ៣៩.៦៥២.៦៧២ | ១៦១.៥៨៤.៦៣៩ |

យោងតាមកំណត់សម្គាល់ ៣០.២ លើហានិភ័យឥណទានសម្រាប់គុណភាពឥណទាន។

## ៧. ឥណទាន និង បុរេប្រទាន (តពីទំព័រមុន)

គ) ការវិភាគសំណុំឥណទានតាមប្រភេទអាជីវកម្ម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| **វិស័យហិរញ្ញវត្ថុ:** | | | | |
| វិស័យហិរញ្ញវត្ថុ | ៣.៩៩០.៨១១ | ១៦.១៦២.៧៨៤ | ២.១៨៨.៤៣៧ | ៨.៩១៧.៨៨១ |
| **មិនមែនវិស័យហិរញ្ញវត្ថុ:** | | | | |
| អចលនទ្រព្យ និង សកម្មភាពជួល | ២០.៣៨៩.១១២ | ៨២.៥៧៥.៩០២ | ៨.៥៦៧.៦៦២ | ៣៤.៩១៣.២២៣ |
| ពាណិជ្ជកម្មលក់ ដុំ និងរាយ | ១៤.២៨១.៣៩៦ | ៥៧.៨៣៩.៦៥៤ | ៤.៥៣៧.២៦៥ | ១៨.៤៨៩.៣៥៥ |
| គេហដ្ឋាន | ៧.១០៩.៩១៧ | ២៨.៧៩៥.១៦៥ | ៨.៣៩១.៩៣៦ | ៣៤.១៩៧.១៣៩ |
| សណ្ឋាគារ និង ភោជនីយដ្ឋាន | ៦.១០៨.៩៨០ | ២៤.៧៤១.៣៦៧ | ២.១៥៦.០១៧ | ៨.៧៨៥.៧៦៩ |
| កម្មន្តសាលកម្ម | ៥.៦៦៥.៥៦៥ | ២២.៩៤៥.៥៣៧ | ២.៧៥៧.៥០០ | ១១.២៣៦.៨១៣ |
| កសិកម្ម | ១.២៧២.០៣៣ | ៥.១៥១.៧៣៥ | ៣២០.៨០៣ | ១.៣០៧.២៧២ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ១.០៥៨.០៦៤ | ៤.២៨៥.១៦១ | ៨០.៣៥៨ | ៣២៧.៤៥៩ |
| សំណង់ | ៤០០.៦៩៥ | ១.៦២២.៨១៣ | ២.២២៤.៧៦៥ | ៩.០៦៥.៩១៧ |
| ដឹកជញ្ជូន ស្តុក និង ទូរគមនាគមន៍ | ៧៦.៩៨៩ | ៣១១.៨០៥ | - | - |
| អាជីវកម្មរ៉ែ | ២១.៦៧២ | ៨៧.៧៧២ | - | - |
| ផ្សេងៗ | ៩.៨៩៨.៦៥២ | ៤០.០៨៩.៥៤៤ | ៨.៤២៧.៩២៩ | ៣៤.៣៤៣.៨១១ |
| **សរុប** | **៧០.២៧៣.៨៨៦** | **២៨៤.៦០៩.២៣៩** | **៣៩.៦៥២.៦៧២** | **១៦១.៥៨៤.៦៣៩** |

ឃ) ការវិភាគឥណទាន និងបុរេប្រទានតាមកាលកំណត់សងសូមមើលកំណត់សម្គាល់លេខ ៣១ ស្តីពី "ការវិភាគសាច់ប្រាក់ងាយស្រួល"។

### ៧. ឥណទាន និង បុរេប្រទាន (តពីទំព័រមុន)



ង) វិភាគឥណទាន និងបុរេប្រទានតាមនិវាសនភាព សម្ព័ន្ធញាតិ ហានិភ័យ និងអត្រាការប្រាក់៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) | ដុល្លារអាមេរិក | សមមូល ពាន់រៀល (កំណត់សម្គាល់ ២.១) |
| តាមនិវាសនភាព៖ | | | | |
| និវាសនជន | ៧០.២៧៣.៨៨៦ | ២៨៤.៦០៩.២៣៩ | ៣៩.៦៥២.៦៧២ | ១៦១.៥៨៤.៦៣៩ |
| អនិវាសនជន | - | - | - | - |
| | **៧០.២៧៣.៨៨៦** | **២៨៤.៦០៩.២៣៩** | **៣៩.៦៥២.៦៧២** | **១៦១.៥៨៤.៦៣៩** |
| តាមសម្ព័ន្ធញាតិ៖ | | | | |
| ភាគីសម្ព័ន្ធញាតិ | ១.១០០.០០០ | ៤.៤៥៥.០០០ | ១.៨៤៥.០០០ | ៧.៥១៨.៣៧៥ |
| ពុំមែនភាគីសម្ព័ន្ធញាតិ | ៦៩.១៧៣.៨៨៦ | ២៨០.១៥៤.២៣៩ | ៣៧.៨០៧.៦៧២ | ១៥៤.០៦៦.២៦៤ |
| | **៧០.២៧៣.៨៨៦** | **២៨៤.៦០៩.២៣៩** | **៣៩.៦៥២.៦៧២** | **១៦១.៥៨៤.៦៣៩** |
| តាមហានិភ័យ៖ | | | | |
| ពុំមែនហានិភ័យធំ | ៧០.២៧៣.៨៨៦ | ២៨៤.៦០៩.២៣៩ | ៣៩.៦៥២.៦៧២ | ១៦១.៥៨៤.៦៣៩ |
| ហានិភ័យធំ | - | - | - | - |
| អត្រាការប្រាក់ប្រចាំឆ្នាំ: | ៧០.២៧៣.៨៨៦ | ២៨៤.៦០៩.២៣៩ | ៣៩.៦៥២.៦៧២ | ១៦១.៥៨៤.៦៣៩ |
| ឥណទានដល់អតិថិជន | | ៧,០០%-២៤,៦០% | | ៧,០០%-២៤,០០% |
| ឥណទានបុគ្គលិក | | ៦,០០%-៩,០០% | | ៦,០០% |

### ៨. វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ការវិនិយោគនេះបង្ហាញពី ភាគកម្មរបស់ធនាគារ ១០០% ជាការវិនិយោគដោយ ក្រុមហ៊ុនមូលបត្រ HwangDBS កម្ពុជាដែលធ្វើអាជីវកម្ម តាំងពី ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០។ ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនគ្មានសកម្មភាព និង មិនបានចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួនទេ។ នាកាលបរិច្ឆេទ នៃរបាយការណ៍នេះ សកម្មភាពជំរះបញ្ជីកំពុងដំណើរការ។ព័ត៌មានហិរញ្ញវត្ថុបុត្រសម្ព័ន្ធនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និង សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានដូចខាងក្រោម៖

| | ដុល្លារអាមេរិក (មិនបានធ្វើសវនកម្ម) |
|---|---|
| សាច់ប្រាក់នៅធនាគារ | ៤.៩៧២.៧២៧ |
| មូលធន | ៤.៩៧២.៧២៧ |
| ខាតសុទ្ធក្នុងឆ្នាំ | ៤០ |

## ៩. ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខាររបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | ការកែលំអអគារ | បរិក្ខារការិយាល័យ | សង្ហារឹម និងបរិក្ខារ | កុំព្យូទ័រ | យានយន្ត | សំណង់កំពុងសាងសង់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៣០៣.០៨៩ | ៦៥៣.២២៤ | ៥២០.៥៥៣ | ៥៦៣.៥២២ | ៤៦.៣០៦ | ១៤៨.២០៤ | ២.២៣៤.៨៩៨ |
| ទិញបន្ថែម | ៦២៦.៧៤៩ | ៤០០.៤១៩ | ២៣៦.៨៧០ | ១០០.៦៤៦ | - | ៧១.៧៧៨ | ១.៤៣៦.៤៦២ |
| ការលុបចោល | (១៣.៩៨២) | - | (១៨.៥៨០) | (៤.៧៤៦) | - | - | (៣៧.៣០៨) |
